**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការធ្វើទេសន្តរប្រវេសន៍ អន្តរជាតិរបស់ពលករនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥


ស្រាវជ្រាវដោយ

សមណនិស្សិតឈ្មោះ **នីឡា វង្សវិស័ក្ត**

សាស្ត្រាចារ្យណែនាំ

លោក **កែម សម្បត្តិ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១

ឆ្នាំសរសេរសារណា ២០១៥

# អារម្ភកថា

ក្រោយពីបានទទួលការសិក្សា និង ធ្វើការស្រាវជាវ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល បួនឆ្នាំ និងដើម្បីឈានទៅបញ្ចប់ការសិក្សាជាស្ថាពរ និងអាចទទួលបានសញ្ញាបត្រ បរិញ្ញាបត្រនីតិសាស្ត្រ ប្រកបដោយជោគជ័យ សាកលវិទ្យាល័យ បានតម្រូវឱ្យនិស្សិតម្នាក់ៗ ជ្រើសរើសប្រធានបទមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ សរសេរជារបាយការណ៍ស្រាវជ្រាវ ឬ សរសេរសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ និង បញ្ជាក់ពីចំណេះដឹងរបស់ខ្លួនដែលបានទទួលនៅសាកលវិទ្យាល័យនេះ។

ដូច្នេះ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ការធ្វើទេសន្តរប្រវេសន៍អន្តរជាតិរបស់ពលករនៅកម្ពុជា**"។ គោលបំណងស្វែងយល់ឱ្យបានច្បាស់លាស់ ពីមូលហេតុ លក្ខខណ្ឌ និងកត្តាផ្សេងៗ ទៀតដែលជំរុញឱ្យប្រជាពលរដ្ឋខ្មែរជាច្រើន បានបង្ខំចិត្តចាកចេញពី ភូមិកំណើត ឃ្លាតឆ្ងាយពីលោកឪពុក អ្នកម្តាយជាទីស្រលាញ់ បែកឆ្ងាយពី បងប្អូនប្រុសស្រី ធ្វើអន្តោប្រវេសន៍ពីតំបន់ជនបទ ឬ តំបន់ទីក្រុង ទៅកាន់ប្រទេសក្រៅ។

ជាចុងក្រោយ ខ្ញុំសុំបញ្ជាក់ថាឯកសាររបាយការណ៍ស្រាវជ្រាវនេះ ជាស្នាដៃមួយដែលមិនមានលក្ខណៈល្អឥតខ្ចោះនោះទេ អាចមានកំហុសឆ្គង និងចំនុចខ្វះខាតមួយចំនួន។ តែខ្ញុំបាទសង្ឃឹមថា ឯកសាររបាយការណ៍ស្រាវជ្រាវនេះ វាមានប្រយោជន៍សម្រាប់និស្សិតច្បាប់ជំនាន់ក្រោយៗ និងបុគ្គលផ្សេងទៀត ដែលមានបំណងស្វែងរកឯកសារទាក់ទងនឹងទេសន្តរប្រវេសន៍អន្តរជាតិ យកមកធ្វើការសិក្សារៀនសូត្រ និង ស្រាវជ្រាវ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **នីឡា ចន្ទវិស័ក្ក** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរព និង ថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅដល់៖

លោកឪពុក **សយ ភានី** និងអ្នកម្ដាយ **ស្រីផល្លា** ដែលលោកទាំងពីរបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា ទូន្មានប្រៀបប្រដៅ និងផ្ដល់ដំបូន្មានល្អៗ ដល់រូបកូនឱ្យខិតខំតស៊ូរៀនសូត្រ ដោយប្ដូរនឹងកម្លាំងញើសឈាមរបស់លោកទាំងពីរដែលខិតខំពុះពាររាល់គ្រប់ឧបសគ្គ ទាំងថ្ងៃទាំងយប់ ដើម្បីរកប្រាក់ឱ្យកូនខំរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ បញ្ចប់ថ្នាក់សិក្សាបរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយជោគជ័យ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីប្រធាន អនុប្រធានការិយាល័យគ្រប់ផ្នែក លោក លោកស្រី សាស្ត្រាចារ្យគ្រប់ជំនាញ មន្ត្រីរាជការបុគ្គលិកទាំងអស់នៃ សាកលវិទ្យាល័យភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោកសាស្ត្រចារ្យ **កែម សម្បត្តិ** ជាសាស្ត្រាចារ្យច្បាប់នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយកម្លាំងកាយកម្លាំងចិត្ត និង ពេលវេលាដ៏មានតម្លៃក្នុងការ ខិតខំចង្អុលបង្ហាញដល់រូបខ្ញុំ ហើយថែមទាំងជាសាស្ត្រចារ្យដឹកនាំក្នុងការសរសេររបាយការណ៍បញ្ចប់ការសិក្សានេះទៀតផង។

លោក **ទូ ម៉ុនផន** ជាអនុប្រធាននាយកដ្ឋានមុខរបរនិងការងារហត្ថពលកម្មដែលបានជួយផ្ដល់នូវឯកសារទាក់ទងនឹងការស្រាវជ្រាវ ព្រមទាំងចំណាយកម្លាំងកាយកម្លាំងចិត្ត និង ពេលវេលាដ៏មានតម្លៃក្នុងការ ណែនាំបន្ថែមដល់រូបខ្ញុំបាទ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យគ្រប់ផ្នែក លោក លោកស្រី សាស្ត្រាចារ្យគ្រប់ជំនាញ មន្ត្រីរាជការ បុគ្គលិកទាំងអស់ ព្រមទាំងមិត្តរួមថ្នាក់ នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឱ្យជួបតែសេចក្ដីសុខចម្រុងចម្រើន ប្រកបដោយសុភមង្គល ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អំណះអំណាង

ខ្ញុំបាទ នីឡា វង្សវិស័ក្ក អក្សរឡាតាំង NYLA VONGVISAK ភេទប្រុស កើតថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ១៩៩៤ សង្កាត់ទួលទំពូងមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ។ អាសយដ្ឋានបច្ចុប្បន្ននៅសង្កាត់ចោមចៅ ខណ្ឌពោធ៍សែនជ័យ រាជធានីភ្នំពេញ ជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការធានាអះអាង និងទទួលខុសត្រូវទាំងស្រុងលើខ្លឹមសារ នៃឯកសារនេះ ដែលពិតជាស្នាដៃ នៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទពិតប្រាកដមែន។

រាជធានីភ្នំពេញ ថ្ងៃទី ......... ខែ.......... ឆ្នាំ២០១៤

ហត្ថលេខា

នីឡា វង្សវិស័ក្ក

# មាតិកា

**អារម្ភកថា** ........ i

**សេចក្តីថ្លែងអំណរគុណ** ........ ii

**អំណះអំណាង** ........ iii

**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១៖ ទេសន្តរប្រវេសន៍អន្តរជាតិ** ........ ៣

១.១ មូលហេតុដែលនាំឱ្យមានទេសន្តរប្រវេសន៍ការងារ ........ ៣

១.១.១ វិស័យការងារនៅប្រទេសកម្ពុជា ........ ៣

១.១.២ សម្ពាធប្រជាសាស្ត្រ ........ ៣

១.១.៣ ការខ្វះខាតពលករនៅក្រៅប្រទេស ........ ៤

១.១.៤ កត្តាជំរុញ ........ ៥

១.១.៥ កត្តាអូសទាញ ........ ៦

១.២ ព័ត៌មានទាក់ទងនឹងទេសន្តរប្រវេសន៍ ........ ៧

១.៣ ទីភ្នាក់ងាររកការងារ និង បញ្ជូនពលករទៅក្រៅប្រទេស ........ ៨

១.៤ កាតព្វកិច្ចរបស់ភាគីពលករមុនធ្វើទេសន្តរប្រវេសន៍ ........ ៨

១.៤.១ ការអនុវត្តកិច្ចសន្យា ........ ១០

១.៤.២ ការវិលត្រឡប់ និងការបញ្ជូនឲ្យវិលត្រឡប់ ........ ១១

**ជំពូកទី ២៖ គុណសម្បត្តិ និង គុណវិបត្តិនៃពលករទេសន្តរប្រវេសន៍** ........ ១៣

២.១ សារៈប្រយោជន៍នៃពលករទេសន្តរប្រវេសន៍ ........ ១៣

២.១.១ លំហូរប្រាក់បញ្ញើប្រឡប់មកស្រុក ........ ១៣

២.១.២ ចំណូល ផ្ញើប្រាក់មកក្រុមគ្រួសារ ........ ១៤

២.១.៣ ជំនាញទទួលបានបទពិសោធន៍ការងារ ........ ១៥

២.១.៤ សន្សំប្រាក់សម្រាប់អនាគត ........ ១៥

២.១.៥ ជួយគ្រួសារដើម្បីវិនិយោគ កសិដ្ឋាន ឬ អាជីវកម្ម ..................................... ១៦
២.១.៦ ចំនេះដឹងខាងវប្បធម៌ខាងក្រៅ ..................................... ១៦
២.២ គុណវិបត្តិនៃពលករទេសន្តរប្រវេសន៍ ..................................... ១៦
២.២.១ ហានិភ័យពាក់ព័ន្ធនឹងចំណាកស្រុក ..................................... ១៦
២.២.២ ការរំលោភបំពានលើសិទ្ធិការងារ ..................................... ១៦
២.២.៣ ការកេងប្រវ័ញ្ចលើការងារ ..................................... ១៧
២.២.៤ បរិយាកាសការងារគ្មានសុវត្ថិភាព ការគំរាមកំហែង..................................... ១៨
២.២.៥ អារម្មណ៍កណ្ដោចកណ្ដែង ឬ ឯកោ ..................................... ១៨
២.២.៦ ចំណងគ្រួសារអាចបែកបាក់ ..................................... ១៨
**ជំពូកទី ៣៖ ទីផ្សារការងារដែលពលករកម្ពុជាធ្វើទេសន្តរប្រវេសន៍** ..................... ២០
៣.១ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេសថៃ ..................................... ២០
៣.១.១ស្ថានភាពរបស់ពលករខ្មែរក្រោយពីបញ្ជូនមកពីថៃវិញ ..................................... ២០
៣.១.២ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅប្រទេសថៃ ..................................... ២០
៣.១.៣ ស្ថានភាពពលករទៅធ្វើការងារនៅប្រទេសថៃ ..................................... ២១
៣.២ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេសម៉ាឡេស៊ី..................................... ២២
៣.២.១ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅប្រទេសម៉ាឡេស៊ី..................................... ២២
៣.២.២ ស្ថានភាពពលករទៅធ្វើការងារនៅប្រទេសម៉ាឡេស៊ី ..................................... ២៤
៣.៣ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេស..................................... ២៥
៣.៣.១ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅសាធារណៈរដ្ឋកូរ៉េ..................................... ២៥
៣.៣.២ ស្ថានភាពពលករទៅធ្វើការងារនៅសាធារណៈរដ្ឋកូរ៉េខាងត្បូង..................................... ២៦
**ជំពូកទី ៤៖ ដំណោះស្រាយចំពោះគុណវិបត្តិ និងលទ្ធផលដែលសម្រេចបាន**.... ២៧
៤.១ ណែនាំវិធីការពារខ្លួននឹងការរំលោភបំពានសិទ្ធិការងារដល់ពលករ ..................................... ២៧
៤.២ កាត់បន្ថយការធ្វើទេសន្តរប្រវេសន៍ក្រៅប្រទេស ..................................... ២៧

៩.៣ វិធានការបង្កើនសុវត្ថិភាពចំណាកស្រុករបស់ក្រសួងការងារ ................................ ២៨
៩.៤ លទ្ធផលរបស់រដ្ឋាភិបាលដែលសម្រេចបាន ...................................................... ៣០
**សេចក្ដីសន្និដ្ឋាន** ...................................................................................... ៣២
**អនុសាសន៍** ............................................................................................. ៣៣
**គន្ថនិទ្ទេស**

# តារាង

តារាង 1 ៖ ប្រជាជនតាមក្រុមអាយុ និង ភេទនៅកម្ពុជា ឆ្នាំ១៩៩៨,២០១០,២០២០ (ចំណោល).... ៤
តារាង 2 ៖ ចំណូលប្រាក់បញ្ញើមកប្រទេសកម្ពុជា (២០០៥-២០០៨)........................................១៤
តារាង 3 ៖ ចំនួនពលករដែលធ្វើការងារនៅប្រទេសថៃ (២០១២-២០១៤)................................ ២២
តារាង 4 ៖ ចំនួនពលករដែលធ្វើការងារនៅប្រទេសម៉ាឡេស៊ី (២០១២-២០១៤)........................២៤
តារាង 5 ៖ ប្រភេទការងារ និង ចំនួនពលករដែលទៅធ្វើការងារនៅកូរ៉េ (២០០៧-២០១៣) .........២៦

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ការធ្វើទេសន្តរប្រវេសន៍ការងារអន្តរជាតិ គឺជាបាតុភូតប្រពៃណីដ៏យូលង់មួយ និងកំពុងតែបន្តកើតមាន។ ទេសន្តរប្រវេសន៍ការងារ (ចំណាកស្រុក) ជាដំណើរការដែលបម្លាស់ទីពីកន្លែងមួយទៅ កន្លែងមួយទៀត ដើម្បីរស់នៅ និងធ្វើការជាបណ្តោះអាសន្ន។

ចាប់តាំងពីឆ្នាំ ១៩៩៥ ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយដែលបញ្ជូនពលករចេញទៅ ធ្វើការងារក្រៅប្រទេសយ៉ាងសំខាន់ទៅកាន់ប្រទេសអាស៊ី ដូចជាប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង និង ប្រទេសមួយចំនួនទៀតដូចជា ជប៉ុន ព្រមទាំងប្រទេសនៅតំបន់ឈូងសមុទ្រដូចជា អារ៉ាប់ អាមេរិក និងកាតាជាដើម។

ការធ្វើទេសន្តរប្រវេសន៍ការងារអន្តរជាតិនេះ គឺជាពិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រសំខាន់ៗ ទាំងឡាយសម្រាប់ប្រជាពលរដ្ឋក្រីក្រកម្ពុជារំដោះខ្លួនពីភាពក្រីក្រ។ ការធ្វើទេសន្តរប្រវេសន៍ការងារអន្តរជាតិរបស់ប្រជាជនកម្ពុជាត្រូវបានកំណត់ និងបានចែងនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ រដ្ឋាភិបាល បានជំរុញនាំចេញ កម្លាំងពលកម្មដោយស្រប់ច្បាប់ក្នុងគោលបំណងបង្កើនសុខុមាលភាព បង្កើនជំនាញវិជ្ជាជីវៈ កាត់បន្ថយភាពអត់ការងារធ្វើ និងបង្កើនប្រាក់ចំណូលរបស់រដ្ឋ។

រយៈពេលប៉ុន្មានឆ្នាំនេះ មានបញ្ហាមួយចំនួនបានកើតឡើងចំពោះប្រជាពលរដ្ឋខ្មែរដែលបានធ្វើទេសន្តរប្រវេសន៍ទៅកាន់ក្រៅប្រទេស។ មានប្រជាពលរដ្ឋកម្ពុជាដែលបម្រើការងារតាមផ្ទះត្រូវបានម្ចាស់ផ្ទះមានការគម្រាម វាយធ្វើបាប និង បង្កឱ្យមានរបួសដល់រូបរាងកាយ ដែលរហូតដល់រដ្ឋាភិបាលកម្ពុជាបានប្រកាសបញ្ឈប់បញ្ជូនពលករទៅធ្វើការងារនៅប្រទេសមួយចំនួន ជាពិសេសគឺទៅកាន់ប្រទេសម៉ាឡេស៊ី តែម្តង។ ថ្មីៗនេះផងដែរ ពលករខ្មែរទាំងស្របច្បាប់ និង មិនស្របច្បាប់ជាច្រើនរូប ត្រូវបានបញ្ជូនមកក្នុងប្រទេសកម្ពុជាវិញ ដោយចោទថាពួកគាត់ បានធ្វើអន្តប្រវេសន៍ខុសច្បាប់ចូលទៅធ្វើការនៅក្នុងប្រទេសថៃ។

តែទោះជាយ៉ាងណាក៏នៅមានប្រជាជនជាច្រើននៅតែ សម្រេចទៅធ្វើការងារនៅក្រៅប្រទេសតាមរយៈមេខ្យល់ ឬ តាមក្រុមហ៊ុនមួយចំនួនដដែល។ ពលករខ្លះក៏ទៅបម្រើការងារនៅក្រៅប្រទេសក្រៅដោយមានឯកសារ ត្រឹមត្រូវនឹងស្របច្បាប់ តែមួយចំនួនទៀតក៏បានទៅរកការងារនៅប្រទេសក្រៅដោយខុសច្បាប់។

ដោយសារកំណើនសេដ្ឋកិច្ច និងការងារនៅក្នុងប្រទេសកម្ពុជាត្រូវបានប្រមូលផ្តុំដោយចង្អៀតនៅក្នុងវិស័យកសិកម្ម កាត់ដេរ សំណង់ និងទេសចរណ៍ ដូច្នេះការជម្រុញមុខរបរក្រៅប្រទេសតាមរយៈសេវាមុខរបរ ឯកជន និងសាធារណៈ គឺជាមូលដ្ឋានមួយសម្រាប់កាត់បន្ថយភាពក្រីក្រ។

# ជំពូកទី ១
# ទេសន្តរប្រវេសន៍អន្តរជាតិ

# ជំពូកទី ១៖ ទេសន្តរប្រវេសន៍អន្តរជាតិ

## ១.១ មូលហេតុដែលនាំឱ្យមានទេសន្តរប្រវេសន៍ការងារ

### ១.១.១ វិស័យការងារនៅប្រទេសកម្ពុជា

សេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនគួរឱ្យកត់សម្គាល់ ចាំពីក្នុងបំឡុងឆ្នាំ ១៩៩៤-២០០៧។ តែនៅក្នុងឆ្នាំ ២០០៨ ខណៈពេលដែលវិបត្តិសេដ្ឋកិច្ចពិភពលោកបានជះឥទ្ធិពលដល់ប្រទេសកម្ពុជា កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ប្រមាណធ្លាក់ចុះ ៦%។[1]

នៅខណៈពេលដែលធ្លាក់ចុះ ដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោកបានធ្វើឱ្យប្រទេសកម្ពុជា កើននូវចំនួននិកម្មជន អ្នកធ្វើការងារក្រីក្រ និង អ្នកដែលស្ថិតក្នុងការងារដែលងាយរងគ្រោះ។ នៅក្នុងប្រទេសកម្ពុជា ឱកាសការងារមានតិចតួចសម្រាប់ស្ត្រីដែលមានជំនាញតិចតួរ លើលែងតែនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរប៉ុណ្ណោះ។ នៅក្នុងឆ្នាំ ២០០៥ ចំណោមផលិតផលនាំចេញសរុបរបស់ប្រទេសកម្ពុជា ផលិតិផលឧស្សាហកម្មកាត់ដេរ មានចំនួនរហូតដល់ ៨០.៤ ភាគរយ ដែលកម្មករកាត់ដេរមាន ប្រហែល ៨៥ ភាគរយគឺជាស្ត្រីដែលក្នុងនោះភាគច្រើនគឺជាស្ត្រីដែលមកពីទីជនបទ។

ក្រោយឆ្នាំ ២០០៩ មកសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈល្អប្រសើរ តែដោយសារ កំណើនប្រជាជន ធ្វើឱ្យវិស័យការងារមានលក្ខណៈចង្អៀត និង កម្រៃនៃចំណូលការងារមាន ភាពតិចតួចមិនអាចបំពេញតម្រូវការក្នុងគ្រួសារបានគ្រប់គ្រាន់ ដែលនាំអោយមានពលករមួយចំនួនត្រូវចាកចេញទៅរកការងារធ្វើក្រៅស្រុក។

### ១.១.២ សម្ពាធប្រជាសាស្ត្រ

យោងតាមជំរឿនប្រជាជនឆ្នាំ ២០០៨ ប្រជាជនសរុបនៅប្រទេសកម្ពុជាមានចំនួន ១៣.៤ លាននាក់ដែលរួមមានបុរស ៦.៥លាននាក់ (៤៩%) និង ស្ត្រី ៦.៩លាននាក់ (៥១%)។ ជាមួយនឹងអត្រាកំណើនប្រជាជនប្រចាំឆ្នាំចំនួន ១.៥៤% និងអត្រាបង្កកំណើតសរុបចំនួន ៣.១% នៅចន្លោះឆ្នាំ ១៩៩៨ និង ២០០៨ ប្រជាជនកម្ពុជាត្រូវបានធ្វើចំណោលថានឹងកើនឡើងទៅដល់ ១៩លាននាក់ក្នុងឆ្នាំ២០២០។ ប្រទេសកម្ពុជាមានសមាមាត្រប្រជាជនក្មេងច្រើន។ យោងទៅតាមជំរឿនឆ្នាំ ២០០៨ អ្នកដែលមានក្រោម ១៥ឆ្នាំ មានចំនួន ៣៤% នៃប្រជាជនសរុប។ មកដល់ពេលបច្ចុប្បន្ន ចំនួនប្រជា

[1] ទំព័រទី ៩,១០, ចំណុច ២ គោលនយោបាយ ស្តីពី ទេសន្តរប្រវេសនិការងារសម្រាប់កម្ពុជា, មិថុនា ២០១០

ជនក្មេងដ៏ច្រើនកំពុងឈានចូលដល់ក្នុងកម្លាំងពលកម្ម ដែលទាំងនេះជាលទ្ធផលនៃសន្ទុះកំណើនទារក នៅក្នុងពាក់កណ្ដាលទសវត្សឆ្នាំ ១៩៨០។ រាជរដ្ឋាភិបាលកម្ពុជាត្រូវឆ្លើយតបទៅនឹងការប្រឈម ដែលបណ្ដាលមកពីការកើនឡើងនៃចំនួនប្រជាជនក្មេង ដែលកំពុងស្វែងរកការងារ។[2]

ដោយសារការងារនៅក្នុងស្រុក មិនគ្រប់គ្រាន់ តម្លៃពលករក្នុងស្រុកថោក ផលិតផលកសិកម្មក្នុងស្រុងលក់បានតម្លៃថោក ជំរុញឱ្យប្រជាពលរដ្ឋធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេស។

*តារាង 1 ៖ ប្រជាជនតាមក្រុមអាយុ និង ភេទនៅកម្ពុជា ឆ្នាំ១៩៩៨,២០១០,២០២០ (ចំណោល)[3]*

| អាយុ | ១៩៩៨ | | | ២០១០ | | | ២០២០ | | |
|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី | សរុប |
| **១៥-១៩** | ៦៨០២២៦ | ៦៩៦៥០០ | ១៣៧៦៧២៦ | ៩៣៩០២៧ | ៩១១៤៧៦ | ១៨៥០៥០៣ | ៨២៧១៤៦ | ៨០៤៩៥៨ | ១៦៣២១០៤ |
| **២០-២៤** | ៣៦២៦៥២ | ៤០១០៤៤ | ៧៦៣៦៩៦ | ៨៦០៨១២ | ៨២៩១១៣ | ១៦៨៩៩២៥ | ៨១៨៦១១ | ៨០៣០០៧ | ១៦២១៦១៨ |
| **១៥-២៤** | ១០៤២៨៧៨ | ១០៩៧៥៤៤ | ២១៤០៤២២ | ១៧៩៩៨៣៩ | ១៧៤០៥៥៨៩ | ៣៥៤០៤២៨ | ១៦៤៥៧៥៧ | ១៦០៧៩៦៥ | ៣២៥៣៧២២ |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ "អនុសាសន៍ស្ដីពីចំណោលប្រជាសាស្ត្រ"

### ១.១.៣ ការខ្វះខាតពលករនៅក្រៅប្រទេស

ប្រទេសខ្លះខ្វះខាតកម្លាំងពលកម្មហើយត្រូវការពលករបន្ថែម ឬឯប្រទេសខ្លះទៀតមានពលកររបស់ខ្លួនចង់ទៅការប្រទេសមួយទៀត ដើម្បីការងារមានប្រាក់ខែកាន់តែខ្ពស់ជាងមុន។ ការកើនឡើងនូវតម្រូវការពលកម្ម និងប្រាក់ចំណូលដែលអាចនឹងរកបាននៅក្នុងប្រទេសកំពុងអភិវឌ្ឍ លឿននៅអាស៊ី និង មជ្ឈឹមបូព៌ា គឺជាកត្តាអូសទាញដ៏ចម្បងសម្រាប់ពលករកម្ពុជាដែលមិនមានការងារធ្វើ និងដែលមានការងារធ្វើមិនពេញលេញទៅ ធ្វើការងារនៅក្រៅប្រទេសទោះបីជាការ

[2] ទំព័រទី ១៤, ចំណុច ៣ គោលនយោបាយ ស្ដីពី ទេសន្តរប្រវេសនិការងារសម្រាប់កម្ពុជា, មិថុនា ២០១០

[3] វិទ្យាស្ថានជាតិស្ថិតិ "អនុសាសន៍ស្ដីពីចំណោលប្រជាសាស្ត្រ"

ទៅក្រៅប្រទេសពោរពេញទៅដោយគ្រោះថ្នាក់ជាច្រើន ដូចជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួយដូរមនុស្ស និងការរើសអើងសង្គមក្នុងប្រទេសទទួល។

ប្រសិនបើប្រទេសជាច្រើន ធ្វើកិច្ចព្រមព្រៀងបញ្ជូននិងទទួលពលករ ជាធម្មតា មានប្រព័ន្ធជ្រើសរើសនិងចងក្រងឯកសារ ដើម្បីឱ្យប្រជាជនធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់។ បើពលករមិនធ្វើទៅតាមប្រព័ន្ធនេះទេ ពួកគេនឹងត្រូវបានចាត់ទុកជាជនទេសន្តរប្រវេសន៍គ្មានឯកសារ ហើយអាចនាំអោយមានការចាប់ខ្លួន និងនិរទេស។ ដូច្នេះជាសំខាន់ត្រូវយល់ដឹងអំពីវិធាន និង នីតិវិធីទាំងអស់មុនពេលពលករធ្វើទេសន្តរប្រវេសន៍។

នៅពេលប្រទេសពីរយល់ព្រមផ្លាស់ប្តូរពលករគ្នា រដ្ឋាភិបាលចុះកិច្ចព្រមព្រៀងមួយ អំពីដំណើរការដែលឱ្យសាធារណៈជនយល់ដឹង។

### **១.១.៤ កត្តាជំរុញ**

- ស្វែងរកប្រាក់ចំណូលដែលស្ថិតស្ថេរ និង ជាប់លាប់។ មានប្រជាពលរដ្ឋមួយចំនួនមានការងារមិនជាប់លាប់ដោយ សារគ្មានជំនាញច្បាស់លាស់ ដែលធ្វើឱ្យការចំណាយលើតម្រូវការសំខាន់មិនគ្រប់គ្រាន់។
- រៀនជំនាញ និង ចង់បានបទពិសោធការងារ។ មានប្រជាពលករមួយចំនួនទៅធ្វើការងារដើម្បីរកប្រាក់ចំណូលផង និង ទៅរៀនជំនាញ ព្រមទាំងចង់បានបទពិសោធការងារដើម្បីងាយស្រួលរកការងារឱ្យបានជាប់លាប់នៅពេលប្រលប់មកស្រុកវិញ ដោយសារជំនាញដែលពួកគេបានពីក្រៅប្រទេស។
- ខ្វះឱកាសការងារនៅក្នុងស្រុក (គ្មានការងារធ្វើ)។ ជាបញ្ហាមួយទាក់ទងនឹងសម្ពាធប្រជាជន ដែលមាននៅកម្ពុជាចាំបាច់រកឱកាសការងារនៅក្រៅប្រទេស។
- សន្សំប្រាក់សម្រាប់អនាគត។ ដើម្បីមានប្រាក់សម្រាប់អនាគត ចាំបាច់ត្រូវមានការងារដែលមានប្រាក់បៀវត្សខ្ពស់ ទើបក្រោយធ្វើការចំណាយ មានប្រាក់ទុកធ្វើចំណាយនៅពេលអនាគត។
- ជំពាក់បំណុលគេ ជាកត្តាមួយផលដែរ ដែលនាំឱ្យពលករត្រូវធ្វើចំណាកស្រុក ដើម្បីរកប្រាក់មកសងបំណុល។ ប្រជាពលរដ្ឋនៅទីជនបទមានភាពខ្វះខាត ដែលចាំបាច់ត្រូវខ្ចីប្រាក់ពីធានាគារ ឬ ជនណាម្នាក់ដើម្បីដោះស្រាយជីវភាពក្នុងគ្រួសារ។

- មានប្រជាពលរដ្ឋមួយចំនួនដែលធ្វើការងារក្នុងស្រុកត្រូវបាន បញ្ជូនទៅសាខាផ្សេងនៅប្រទេសក្រៅដែលនាំអោយមានការធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសក្រៅដែលក្រុមហ៊ុនខ្លួនបានបញ្ជូន។

### ១.១.៥ កត្តាអូសទាញ

- ប្រាក់បៀវត្សខ្ពស់ ជាកត្តាមួយដែលបានអូសទាញពលករខ្មែរផងដែរ។ ការងារក្នុងស្រុកទទួលបានប្រាក់ឈ្នួលទាបជាងបើធៀបនឹងប្រទេសក្រៅ ដែលនាំឱ្យពលករខ្មែរសំលឹងលើប្រាក់ទាំងនោះដើម្បីមកចំណាយផ្ទាល់ខ្លួន។
- សម្ភារៈអូសទាញ ក៏ជាកត្តាមួយដែលបានអូសទាញពលករខ្មែរផងដែរ។ ដោយហេតុបច្ចុប្បន្នមានសម្ភារៈទំនើបមួយចំនួនបានចេញលក់លើទីផ្សារធ្វើឱ្យប្រជាពលរដ្ឋខ្លះ ចង់បានដើម្បីប្រើការ សម្រាប់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។
- មានប្រជាជនមួយចំនួនចង់ស្គាល់ប្រទេសក្រៅ ដែលនាំអោយមានការធ្វើចំណាកស្រុករកការងារនៅក្រៅប្រទេស។
- ការធ្វើចំណាកស្រុកដោយខុសច្បាប់ រកការងារក្រៅមានច្រើន។ មានប្រជាជនមួយចំនួនបានរកចេញទៅនៅប្រទេសក្រៅដោយមិនស្រប់ច្បាប់ ដោយសារបញ្ហាមួយចំនួនដូចជា ការរត់គេចខ្លួន ឬ តាមគ្រួសារ។ នៅពេលមានសង្គ្រាម មានប្រជាពលរដ្ឋខ្លះបានរត់គេចខ្លួនទៅប្រទេសជិតខាង។ ប្រជាពលរដ្ឋខ្លះ ក៏បានវិលប្រលប់មកវិញ ដើម្បីជួបជុំគ្រួសារ និង មិត្តភក្តិ។ តែប្រជាពលរដ្ឋខ្លះទៀតបន្តរស់នៅដោយស្របច្បាប់ និងខ្លះទៀតដោយមិនស្របច្បាប់ ហើយពួកគេបានអូសទាញ គ្រួសារដែលនៅក្នុងស្រុករត់មករស់នៅ និង ធ្វើការងារជាមួយគ្នា។
- ចាញ់បោកមេខ្យល់។ មានប្រជាពលរដ្ឋមួយចំនួនតូច ត្រូវបានចាញ់បោកអ្នកដ៏ទៃ ដែលនាំខ្លួនទៅដល់ប្រទេសក្រៅធ្វើការងារដោយមិនពេញ ឬ ដោយមិនបានតាំងចិត្តនឹងធ្វើករក្រៅ។
- មានប្រជាពលរដ្ឋមួយចំនួនដែលធ្វើការងារក្នុងស្រុកត្រូវបាន បញ្ជូនទៅសាខាផ្សេងនៅប្រទេសក្រៅដែលនាំអោយមានការធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសក្រៅដែលក្រុមហ៊ុនខ្លួនបានបញ្ជូន។

- ការធ្វើចំណាកស្រុកតាមគ្នា ។ នេះជាកត្តាដែលកើតឡើងញឹកញាប់ដោយសារប្រជាពលរដ្ឋភាគច្រើន ចង់បានគ្នាធ្វើដំណើរជាមួយដើម្បីកុំអោយមានភាពឯកកោរនៅពេលធ្វើការនៅប្រទេសក្រៅ។

## ១.២ ព័ត៌មានទាក់ទងនឹងទេសន្តរប្រវេសន៍

ព័ត៌មានដែលទាក់ទងនឹងការងារ ដែលមាននៅក្រៅប្រទេសភាគច្រើនមានការផ្សព្វផ្សាយដោយក្រុមហ៊ុនឯកជនតាមរយៈវិទ្យុ ការសែត ឬ ទូរទស្សន៍។ ប៉ុន្តែប្រជាជនក៏អាចទទួលព័ត៌មានទាំងនោះ នៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។ អង្គការស្របច្បាប់មួយចំនួនដែលទាក់ទងនឹង អង្គការពលកម្មអន្តរជាតិក៏មានការផ្សព្វផ្សាយការងារទាំងនោះផងដែរ ដើម្បីធ្វើការជួយស្វែងរកការងារឱ្យពលករនៅប្រទេសកម្ពុជាបានធ្វើ។ អង្គការទាំងនោះមាន មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ដែលជាកន្លែងមួយដែលប្រជាជនអាចមក ទទួលព័ត៌មានអំពីការងារនៅបរទេស។

មណ្ឌលធនធានពលករ ផ្តល់នៅព័ត៌មាន និង ឱវាទស្តីពីអ្វីដែលត្រូវធ្វើដល់ ពលករនៅពេលធ្វើចំណាកស្រុកការងារពោលគឺ ប្រភេទការងារហានិភ័យ និងអត្ថប្រយោជន៍ជាសក្តានុពល ដំណើរការចំណាកស្រុក និង វិធីដែលពលករអាចថែរក្សាខ្លួនឱ្យមានសុវត្ថិភាព ដល់ពលករដែលសម្រេចចិត្តធ្វើចំណាកស្រុក។ នៅមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ជួយដល់ពលករ ឱ្យយល់ពីកិច្ចសន្យានានាដាក់ពាក្យសុំលិខិតឆ្លងដែន និងទិដ្ឋាការ ព្រមទាំងឱ្យឱវាទពលករអំពីការ រកទីភ្នាក់ងារជ្រើសរើសពលករមានអាជ្ញាប័ណ្ណ ហើយក៏មានពិភាក្សាជាមួយពលករអំពីសិទ្ធិ និង ការទទួលខុសត្រូវរបស់ពលករ និង ភ្នាក់ងារជ្រើសរើស និង និយោជក និង មន្ត្រីនានា។

ប្រសិនបើជាមណ្ឌលធនធានពលករ មិនអាចជួយដល់ពលករចំពោះបញ្ហាណាមួយបាន មណ្ឌលធនធានពលករ នឹងបញ្ជូនទៅអង្គការឯទៀតដែលមានលទ្ធភាពជួយដល់ពលករដែលមានបញ្ហាទាំងនោះ។[4]

[4] ទំព័រ ១០១, ចំណុច ៤.១, សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ ២០០៦-២០១៥

## ១.៣ ទីភ្នាក់ងារកេការងារ និង បញ្ជូនពលករទៅក្រៅប្រទេស

ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនឯកជនណាមួយ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការគឺជា **ទីភ្នាក់ងារជ្រើសរើសឯកជន** ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបានចុះកិច្ចសន្យាជាមួយក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ។

ភ្នាក់ងារជ្រើសរើសសំដៅ យកកម្មករនិយោជិតទាំងឡាយណារបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលបានពិនិត្យ និងចេញប័ណ្ណសំគាល់ខ្លួន ដោយអគ្គនាយកដ្ឋានការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ធ្វើការជ្រើសរើសពលករទេសន្តរប្រវេសន៍ សម្រាប់សាមីទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ។

ភ្នាក់ងារជ្រើសរើសទាំងឡាយណា ដែលត្រូវបានទីភ្នាក់ងារជ្រើសរើសឯកជនកំណត់ឱ្យទទួលខុសត្រូវលើការងារទាំងមូលរបស់ក្រុមហ៊ុន ឬ មួយផ្នែកនៃក្រុមហ៊ុនមានសិទ្ធិសម្រេចលើការងារទាំងនោះដោយផ្ទាល់ ដូចជា ការណែនាំតម្រង់ទិស និងការជ្រើសរើសបុគ្គលទៅធ្វើការងារនៅប្រទេសក្រៅជាដើម។[5]

## ១.៤ កាតព្វកិច្ចរបស់ភាគីពលករមុនធ្វើទេសន្តរប្រវេសន៍

ការត្រៀមខ្លួនមុនរបស់ពលករ ជាប្រការសំខាន់បំផុតមុនពេលដែលពលករចាកចេញទៅបំពេញការងារនៅខាងក្រៅ។ គ្រោះថ្នាក់អាចកើតមានចំពោះពលករបើ ពួកគាត់មិនបានដឹង និងត្រៀមខ្លួនជាមួយ។ កាតព្វកិច្ចដែលពលករត្រូវមានព្រមទាំងសិទ្ធរបស់ខ្លួន និងលក្ខខណ្ឌដើម្បីចេញទៅក្រៅ ជារឿងមួយដែលពលករគ្រប់រូបត្រូវដឹង រួមទាំងប្រភេទនៃការចំនាញផ្សេងៗមុនពេលចេញទៅប្រទេសក្រៅ។

ប្រភេទថ្លៃចំណាយនៃចំណាកស្រុកក្រៅប្រទេសរួមមានៈ

- លិខិតឆ្លងដែន
- ទិដ្ឋាការសម្រាប់ធ្វើការ
- លិខិតអនុញ្ញាតអោយធ្វើការ
- ការពិនិត្យសុខភាព

[5] ទំព័រទី ៥, ចំណុច ៥,៦ ប្រកាសលេខ ០៤៥/១៣ក.ប/ប្រក ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣

- ការធ្វើដំណើរក្នុងស្រុក
- សំបុត្រចេញដំណើរ
- ការតម្រង់ទិសការងារ / ការបណ្តុះបណ្តាល
- ថ្លៃជើងសារ
- ថ្លៃស្នាក់នៅ និង អាហារនៅកន្លែងគោលដៅ
- របស់របរផ្ទាល់ខ្លួន (សំលៀកបំពាក់ថ្មី...)

ភាគីពលករ មានកាតព្វកិច្ចមួយចំនួនផ្សេងក្រៅពីសិទ្ធរបស់ខ្លួន និងការចំនាញផ្សេងៗមុនពេលចេញទៅប្រទេសក្រៅ ដូចជាការយល់ដឹងពីច្បាប់ និង តួនាទីមួយចំនួនរបស់ខ្លួន ពីការធ្វើទេសន្តរប្រវេសន៍ ដូចជា ៖

- ពលករត្រូវមានអាយុពី១៨ឆ្នាំឡើង យោងទៅលើឯកសារផ្ទាល់ខ្លួន ស្របច្បាប់គ្រប់គ្រាន់ និងត្រឹមត្រូវដែលត្រូវប្រគល់ជូន ភាគីទីភ្នាក់ងារជ្រើសរើសឯកជន សម្រាប់ការរៀបចំរាល់ឯកសារតាមច្បាប់ និងបទបញ្ញានានារបស់ស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទទួលពលករ
- ត្រួតពិនិត្យឲ្យបានច្បាស់លាស់ លើខ្លឹមសារនៃកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារដូចជា លក្ខខណ្ឌនៃការរស់នៅ លក្ខខណ្ឌការងារ ស្ថានភាពការងារ ប្រភេទការងារ ផលប្រយោជន៍ដែលទទួលបាន និងអាសយដ្ឋានដែលត្រូវធ្វើការទំនាក់ទំនងជាដើម មុននឹងសម្រេចចិត្តចុះហត្ថលេខាលើកិច្ចសន្យានោះ។ សាម៉ីពលករមានសិទ្ធិទទួលយកជនណាម្នាក់ដែលខ្លួនទុកចិត្តឲ្យចូលរួមក្នុងការពិនិត្យ មុននឹងធ្វើការចុះហត្ថលេខាលើកិច្ចសន្យាសេវារកការងារឲ្យធ្វើ និងកិច្ចសន្យាការងារ
- ត្រូវធ្វើការងារជូនតែនិយោជក ដែលខ្លួនបានចុះកិច្ចសន្យាការងារជាមួយតែប៉ុណ្ណោះដោយមិនអាចធ្វើការងារជូននិយោជកណាមួយផ្សេងទៀតឡើយ នៅក្នុងរយៈពេលនៃកិច្ចសន្យាការងារ។ ក្នុងករណីពលករចង់ផ្លាស់ប្តូរនិយោជក លុះត្រាតែធ្វើការពិភាក្សាឯកភាពជាមួយ ភាគីទីភ្នាក់ងារជ្រើសរើសឯកជន ស្របតាមបទបញ្ញត្តិនៃច្បាប់ និងបទបញ្ញានៃប្រទេសទទួល
- ត្រូវរាយការណ៍ជូនក្រុមហ៊ុន ឬ ស្ថានឯកអគ្គរាជទូត ឬ ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បើសិនពលករមានវិវាទ

- ត្រូវទទួលខុសត្រូវចំណាយលើឯកសារ សំបុត្រយន្តហោះ ឬ ថ្លៃធ្វើដំណើរត្រឡប់មកមាតុភូមិ ក្នុងករណីពលករបញ្ចប់កិច្ចសន្យាមុនពេលកំណត់ដោយមូលហេតុផ្ទាល់ខ្លួន
- ត្រូវជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសរបស់ខ្លួន នៅពេលដែលចង់បន្តកិច្ចសន្យាការងារជាថ្មីជាមួយនិយោជក ដើម្បីឲ្យទីភ្នាក់ងារជ្រើសរើសរៀបចំឯកសារបន្តកិច្ចសន្យាស្របច្បាប់ ដោយពលករត្រូវបង់រាល់ចំណាយទាំងឡាយ ដែលជាបន្ទុករបស់ខ្លួន
- ត្រូវបង់អាករ និងធ្វើកាតព្វកិច្ចផ្សេងៗ ស្របតាមការកំណត់របស់ច្បាប់ និងបទបញ្ញានានារបស់ប្រទេសទទួលពលករ
- ត្រូវបង់ប្រាក់សម្រាប់ចំណាយក្នុងការធ្វើឯកសារផ្ទាល់ខ្លួន។ ការចំណាយនេះមិនរាប់បញ្ចូលសេវាផ្សេងៗដែលផ្តល់ឲ្យដោយទីភ្នាក់ងារជ្រើសរើសឯកជនទេ
- ត្រូវគោរពច្បាប់ និងបទបញ្ញាផ្សេងៗនៃប្រទេសទទួលពលករ។[6]

### ១.៤.១ ការអនុវត្តកិច្ចសន្យា

ក្នុងករណី ភាគីពលករ មិនគោរពកិច្ចសន្យា បណ្តាលឲ្យមានការខូចខាតដល់ ភាគីទីភ្នាក់ងារជ្រើសរើសឯកជន ភាគីពលករ ត្រូវទទួលខុសត្រូវជួសជុលសងការខូចខាតទាំងនោះដល់ ភាគីទីភ្នាក់ងារជ្រើសរើសឯកជន។

ក្នុងករណី ភាគីទីភ្នាក់ងារជ្រើសរើសឯកជន មិនគោរពកិច្ចសន្យា បណ្តាលឲ្យមានការខូចខាតដល់ ភាគីពលករ ភាគីទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវទទួលខុសត្រូវជួសជុលសងការខូចខាតទាំងនោះដល់ ភាគីពលករ។

ក្នុងករណីមានវិវាទកើតឡើងពីការអនុវត្តកិច្ចសន្យា ភាគីនីមួយៗត្រូវដោះស្រាយគ្នាតាម រយៈការផ្សះផ្សាតាមនីតិវិធីជាមុន។ ក្នុងករណីមិនអាចដោះស្រាយគ្នាតាមរយៈការផ្សះផ្សាបាន ភាគីម្ខាងមានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ឬ តុលាការ។

ក្នុងករណីភាគីណាមួយចង់រំលាយកិច្ចសន្យានេះ ភាគីនោះត្រូវជូនដំណឹងទៅភាគីម្ខាងទៀត និងត្រូវសងការខូចខាតពីការរំលាយកិច្ចសន្យារបស់ខ្លួន។

[6] អនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១១

### ១.៤.២ ការវិលត្រឡប់ និងការបញ្ជូនឲ្យវិលត្រឡប់

លើកលែងតែមានសេចក្ដីបញ្ជាក់ផ្សេងទៀត រយៈពេលនៃលក្ខខណ្ឌការងាររបស់ពលករ មិនត្រូវឲ្យលើសរយៈពេល ២ឆ្នាំឡើយ។ បើសិនមានការចាំបាច់ រយៈពេលនេះអាចបន្ត ២ឆ្នាំទៀតបាន។ ទោះក្នុងករណីណាក៏ដោយ រយៈពេលនេះមិនត្រូវលើសពី ៤ឆ្នាំឡើយ។ បន្ទាប់ពីនោះកិច្ចសន្យាការងារត្រូវបញ្ចប់។

ចំពោះពលករដែលបានបញ្ចប់កិច្ចសន្យាការងាររួចហើយ ត្រូវផ្អាកកិច្ចសន្យានេះរយៈពេល ៣ឆ្នាំសិន ទើបអាចដាក់ពាក្យសុំទៅធ្វើការងារជាថ្មីទៀតបាន។

ភាគី ត្រូវពង្រីកកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានាការវិលត្រឡប់នៃពលករដែលស្មោះត្រង់ ដែលបានបញ្ចប់កិច្ចសន្យាការងារ ឲ្យទៅកាន់ប្រទេសដើមរបស់ពួកគេវិញ។

ទីភ្នាក់ងារមានសមត្ថកិច្ចនៃប្រទេសដែលប្រើប្រាស់ពលករ ត្រូវបង្កើត និងគ្រប់គ្រងមូលនិធិនៃប្រាក់សន្សំ។ ពលករត្រូវបង់វិភាគទានប្រចាំខែចូលមូលនិធិនេះ ក្នុងចំនួនទឹកប្រាក់សមមូលនឹង ១៥% នៃប្រាក់បៀវត្សប្រចាំខែរបស់ពួកគេ។

ពលករ ដែលបានបញ្ចប់កិច្ចសន្យាការងារ និងបានវិលត្រឡប់មកប្រទេសដើមវិញ មានសិទ្ធិទទួលបានមកវិញទាំងអស់នូវប្រាក់វិភាគទាន ដែលបានបង់ចូលទៅមូលនិធិនៃប្រាក់សន្សំ រួមទាំងការប្រាក់ ដោយត្រូវដាក់ពាក្យស្នើសុំទៅទីភ្នាក់ងារមានសមត្ថកិច្ច ឲ្យបាន៣ខែ មុនកាលវិច្ឆេទនៃការចេញដំណើរបន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ។ ការបើកប្រាក់ជូនពលករវិញនេះ ត្រូវធ្វើឡើងនៅក្នុងរយៈពេល ៤៥ថ្ងៃ បន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ។

ក្នុងករណីដែលពលករបានបញ្ចប់ការងារមុនកាលកំណត់នៃការបញ្ចប់ កិច្ចសន្យាការងារ ហើយត្រូវវិលត្រឡប់ទៅប្រទេសដើមរបស់ពួកគេវិញ ការបើកប្រាក់នេះ និងការប្រាក់ ក៏ត្រូវធ្វើក្នុង រយៈពេល ៤៥ថ្ងៃ បន្ទាប់ពីការបញ្ចប់ការងារដែរ។

ការវិលត្រឡប់ទៅប្រទេសដើមវិញជាបណ្ដោះអាសន្នរបស់ពលករ ដែលកិច្ចសន្យាការងាររបស់ពួកគេនៅមានសុពលភាព ហើយដែលការវិលត្រឡប់នោះ ត្រូវបានអនុវត្តស្របតាមបទបញ្ជារបស់ទីភ្នាក់ងារមានសមត្ថកិច្ច មិនមែនជាមូលហេតុ នៃការផ្ដាច់កិច្ចសន្យាការងារ ដែលមានការអនុញ្ញាត ដូចមានចែងក្នុងប្រការ៤ខាងលើនោះទេ។

នីតិវិធី និងឯកសារដែលតម្រូវឲ្យប្រើក្នុងការដាក់ពាក្យស្នើសុំដកប្រាក់ ដូចមានចែងក្នុងប្រការ១២ ត្រូវរៀបចំបង្កើតឡើងដោយទីភ្នាក់ងារមានសមត្ថកិច្ច។

សិទ្ធិក្នុងការដកប្រាក់វិភាគទាន ដែលបានបង់ចូលទៅក្នុងមូលនិធិនៃប្រាក់សន្សំនេះ នឹងត្រូវបានដកហូតចំពោះពលករណា ដែលមិនវិលត្រឡប់ទៅកាន់ប្រទេសដើមវិញ ក្រោយពេលដែលបញ្ចប់កិច្ចសន្យាការងារ។

ទីភ្នាក់ងារមានសមត្ថកិច្ចនៃប្រទេសដែលប្រើប្រាស់ពលករ អាចដកយកប្រាក់ពីមូលនិធិប្រាក់សន្សំនេះ បំរើការចំណាយរដ្ឋបាលរបស់ធនាគារ និងការចាប់បញ្ជូនពលករឲ្យត្រឡប់ទៅកាន់ប្រទេសដើមវិញ។[7]

[7] អនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១១

# ជំពូកទី ២
# គុណសម្បត្តិ និង គុណវិបត្តិនៃពល
# ករទេសន្តរប្រវេសន៍

# ជំពូកទី ២៖ គុណសម្បត្តិ និង គុណវិបត្តិនៃពលករទេសន្តរប្រវេសន៍

## ២.១ សារៈប្រយោជន៍នៃពលករទេសន្តរប្រវេសន៍

ការចេញធ្វើការងារក្រៅប្រទេសបានផ្តល់ប្រយោជន៍ជាច្រើន ហើយរាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ និង លើកទឹកចិត្តដល់វិនិយោគ ឯកជន សម្រាប់បង្កើនឱកាសការងារក្នុងស្រុកសម្រាប់ប្រជាពលរដ្ឋ ជាពិសេសការអភិវឌ្ឍវិស័យឯកជន និង ការងារដែលមាននៅក្នុងចតុកោណទី ៤ ស្តីពីការកសាងសមត្ថភាព និង ធនធានមនុស្ស។

រាជរដ្ឋាភិបាលយកចិត្តទុកដាក់ ក្នុងការស្វែងរកទីផ្សារការងារល្អនៅក្រៅប្រទេសសម្រាប់ឆ្លើយតបតាមកំណើនប្រជាជន និង តាមតម្រូវការប្រជាពលរដ្ឋ។ ពលករដែលធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ អាចទទួលបានកិច្ចការពារយ៉ាងច្រើនពីអាជ្ញាធរក្រៅប្រទេស រួមទាំងប្រយោជន៍ដ៏ទៃទៀត។[8]

### ២.១.១ លំហូរប្រាក់បញ្ញើប្រឡប់មកស្រុក

ចំណូលដែលបានពីប្រទេសដែលបានអភិវឌ្ឍន៍ មានចំនួនច្រើនជាងប្រទេសដែលកំពុងអភិវឌ្ឍ។ កាលដែលពលករទទួលបានប្រាក់ចំណូលបានច្រើន ក៏ធ្វើឱ្យប្រទេសជាតិមានភាពអភិវឌ្ឍផងដែរ។ ប្រាក់បញ្ញើដែលបានត្រឡប់សម្រាប់ប្រទេសកម្ពុជា គឺមានប្រហែលជា ៣២៥ លានដុល្លារអាមេរិកជាក្នុងឆ្នាំ២០០៨ ទៅអោយក្រុមគ្រួសាររបស់ពលករ។ កន្លងមកប្រព្រ័ន្ធផ្ទេរប្រាក់ប្រឡប់មកស្រុកវិញ ដែលពេញនិយមជាងគេ គឺការផ្ទេរប្រាក់តាមប្រព័ន្ធទូរស័ព្ទ (៦១ ភាគរយ) តាមសាច់ញាតិ (៣២ ភាគរយ) តាមអ្នកនាំសារ (៤ ភាគរយ) ដោយពលករខ្លួនឯង និងតាមធនាគាររបស់ក្រុមហ៊ុន និងផ្សេងៗទៀត។

យោងតាមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការប៉ានប្រមាណអំពីប្រាក់បញ្ញើត្រឡប់ ដែលប្រទេសកម្ពុជាទទួលបានពីពលករ ទៅធ្វើការនៅប្រទេសកូរ៉េមានចំនួនទឹកប្រាក់ប្រហែល ៤៨ លានដុល្លាអាមេរិក ដែលបានបញ្ជូនជារៀងរាល់ឆ្នាំ។ ពលករទទួលបានប្រាក់បៀវត្សប្រចាំខែមិនទាបជាង ៨០០ ដុល្លា ទៅ ១.០០០ ដុល្លាអាមេរិកទេ។ នៅក្នុងរោងចក្រមួយចំនួនក្នុងប្រទេសកូរ៉េមានការងារធ្វើបន្ថែមសម្រាប់ពលករដែលមានជំនាញ ធ្វើឱ្យពួកគេរកប្រាក់ចំណូលបាន

[8] ទំព័រទី ១៩, ២០, ២១, ចំណុច ៤.២ ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆិកា ២០០៩

រហូតដល់ ២០០០ដុល្លា ក្នុងមួយខែ។ ចំណែកឯពលករដែលមានជំនាញធ្វើការនៅប្រទេសម៉ាឡេស៊ីវិញមាន ១៥០ ដុល្លារ ហើយប្រាក់បញ្ញើត្រលប់មកស្រុកវិញមានចំនួនសរុបប្រហែលជា ២២ លានដុល្លាក្នុងមួយឆ្នាំ។ សម្រាប់ពលករដែលមានជំនាញធ្វើការនៅប្រទេសថៃវិញមាន ១៥០ ដុល្លារ ហើយប្រាក់បញ្ញើត្រលប់មកស្រុកវិញមានចំនួនសរុបប្រហែលជា ១៤ លានដុល្លាក្នុងមួយឆ្នាំ។[9]

ចំនួនទឹកប្រាក់បញ្ញើដែលបានត្រឡប់មកប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ពិតជាគុណាសម្បត្តិ និង ជាអត្តប្រយោជន៍មួយ ដែលបានចូលរួមកាន់បន្ថយភាពក្រីក្រមួយផ្នែកនៅកម្ពុជាផងដែរ។

*តារាង 2 ៖ ចំណូលប្រាក់បញ្ញើមកប្រទេសកម្ពុជា (២០០៥-២០០៨)*[10]




ស្ថិតិពីធានាគារពិភពលោក (២០០៩)

### ២.១.២ ចំណូល ផ្ញើប្រាក់មកក្រុមគ្រួសារ

ដោយសារជីវភាពគ្រួសារ ប្រជាជនកម្ពុជាជាច្រើនបានចាត់ទុកថាការទៅធ្វើការងារនៅក្រៅប្រទេស ជាមធ្យោបាយមួយសម្រាប់រំដោះខ្លួនចេញពីភាពក្រីក្រ ហើយប៉ុន្មានឆ្នាំកន្លងមក ពលករជា

[9] ទំព័រទី ១៦,១៧, ១៨, ចំណុច ៥.១ ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆិកា ២០០៩

[10] ធានាគារពិភពលោក ឆ្នាំ ២០០៩

ច្រើនធ្វើទេសន្តរប្រវេសន៍រកការងារធ្វើនៅក្រៅប្រទេសដើម្បីជួយជីវភាពគ្រួសារ និងរំដោះខ្លួនចេញពីភាពក្រីក្រ។

នៅពេលពលករចេញធ្វើការនៅក្រៅនាំមកនៅ ជំនាញ និងបទពិសោធន៍ រួមទាំងបានបញ្ជូនប្រាក់បញ្ញើផ្ញើត្រលប់មកជូនដល់គ្រួសារ ឬ អ្នកផ្ទះវិញទៀតផង។ ប្រាក់បញ្ញើ បានបង្កើននូវលទ្ធភាពចំនាយរបស់ ក្រុមគ្រួសារ ដែលអាចឱ្យពួកគេចំណាយកាន់តែច្រើនទៅលើការប្រើប្រាស់ប្រចាំថ្ងៃ សេវាសុខាភិបាល អប់រំ និង សងបំណុល ក៏ដូចជាសន្សំបន្ថែមទៀតផងដែរ។ ប្រាក់បញ្ញើបានធ្វើឱ្យស្តង់ដាររស់នៅរបស់ក្រុមគ្រួសារកើនឡើង និងចូលរួមកាត់បន្ថយភាពក្រីក្រ។[11] ប្រាក់បញ្ញើក្លាយជាប្រភពចំណូលដ៏សំខាន់ ក្នុងក្រុមគ្រួសារ បើតាមរបាយការណ៍ និង ការសាកសួរសមាជិកគ្រួសារមួយចំនួន។

### ២.១.៣ ជំនាញទទួលបានបទពិសោធន៍ការងារ

មានពលករជាច្រើនបានទទួលការបណ្តុះបណ្តាលមុនពេលចេញទៅបំពេញការងារ នៅប្រទេសក្រៅ។ ការបណ្តុះបណ្តាលជាកត្តាសំខាន់ ដោយសារការបណ្តុះបណ្តាលនាំអោយពលករមានជំនាញច្បាស់ និងមិនត្រូវបានធ្វើឱ្យមានកំហុសកើតឡើងញឹកញាប់នៅពេលបំពេញការងាររបស់ខ្លួន។

នៅពេលពលករចេញបានធ្វើការនៅក្រៅប្រទេស ពលករក៏អាចទទួលបានចំណេះដឹងថ្មីផ្សេងថែមទៀតទៅតាមកន្លែងការងារដែលខ្លួនបានធ្វើ។

### ២.១.៤ សន្សំប្រាក់សម្រាប់អនាគត

ពេលពលករចេញបានធ្វើការនៅក្រៅប្រទេស ពួកគាត់បានបញ្ជូនប្រាក់បញ្ញើផ្ញើត្រលប់មកជូនដល់គ្រួសារ ក៏ដូចជាសន្សំសម្រាប់ការប្រើប្រាស់ខ្លួនឯង នៅពេលអនាគតផងដែរ ដូចជាសម្រាប់ធ្វើជំនួញ និង យកបទពិសោធន៍ដែលខ្លួនមានពីប្រទេសដ៏ទៃ រួមទាំងប្រាក់សន្សំខ្លួន មកធ្វើការរកស៊ីខ្លួនឯងផងដែរ។

[11] ទំព័រទី ១៩ ចំណុច ៤.២, គោលនយោបាយ ស្តីពី ទេសន្តរប្រវេសនិការងារសម្រាប់កម្ពុជា, មិថុនា ២០១០

### ២.១.៥ ជួយគ្រួសារដើម្បីវិនិយោគ កសិដ្ឋាន ឬ អាជីវកម្ម

វិស័យកសិកម្មជា វិស័យដ៏សំខាន់មួយក្នុងប្រទេសកម្ពុជា ដែលមានប្រជាជនជាច្រើន ធ្វើជាការងារចិញ្ចឹមជីវិត។ ប្រាក់បញ្ញើបានធ្វើឱ្យស្តង់ដាររស់នៅរបស់ក្រុមគ្រួសារកើនឡើង ក៏បានជួយដល់គ្រួសារដើម្បីការងារវិនិយោគ លើវិស័យកសិកម្ម ឬ អាជីវកម្មរបស់ខ្លួនឱ្យមានលក្ខណៈប្រសើរឡើង។

### ២.១.៦ ចំនេះដឹងខាងវប្បធម៌ខាងក្រៅ

ពលករត្រូវតែមានការអប់រំនូវចំនេះដឹងទូទៅមុនពេលទៅបំពេញការងារខាងក្រៅ។ តែពលករផ្ទាល់ត្រូវតែចេះសម្របខ្លួនទៅតាមបរិស្ថានដែលខ្លួននៅ។ ចំនេះដឹងដែលបានមកពីការអប់រំ និងបទពិសោធន៍ផ្ទាល់ របស់ពលករ ជួយអោយពលករទទួលចំនេះដឹងបន្ថែមលើអ្វីដែលខ្លួនមានពីមុនមក។

## ២.២ គុណវិបត្តិនៃពលករទេសន្តរប្រវេសន៍

### ២.២.១ ហានិភ័យពាក់ព័ន្ធនឹងចំណាកស្រុក

ជួនកាលទីភ្នាក់ងារជ្រើសរើស ឬ និយោជកដាក់ពលករធ្វើការងារប្រភេទឯទៀតផ្សេងពីការងារ ដែលខ្លួនបានព្រមព្រៀង។ ឧទាហរណ៍ ពលករភេទប្រុសម្នាក់រំពឹងថាធ្វើការក្នុងរោងចក្រ ប៉ុន្តែត្រូវបានគេបញ្ជូនឱ្យធ្វើការនៅលើទូកនេសាទ ឬ នៅការដ្ឋានសំណង់ទៅវិញ។ ពលករទេសន្តរប្រវេសន៍ជាស្ត្រី អាចត្រូវបានជ្រើសរើសឱ្យធ្វើរោងចក្រប៉ុន្តែត្រូវបានគេបញ្ជូនឱ្យធ្វើការនៅទីតាំងបំរើផ្លូវភេទ។

ស្ត្រីមានហានិភ័យកាន់តែខ្ពស់ចំពោះការជួញដូរផ្លូវភេទជាងបុរស។ ពលករត្រូវតែប្រាកដអោយច្បាស់អំពីកិច្ចសន្យារបស់ខ្លួន ហើយត្រូវមានការប្រុងប្រយ័ត្នលើកិច្ចសន្យាធ្វើជាអ្នករត់តុ ឬ ជាអ្នកធ្វើការនៅកន្លែងកំសាន្ត។ ជួនកាលនិយោជករំពឹងថាស្ត្រីដែល ចុះកិច្ចសន្យាធ្វើការងារទាំងនេះ ក៏ ធ្វើការងារផ្នែកផ្លូវភេទផងដែរ។ សម្រាប់ប្រទេសថៃ គេបានហាមប្រាមពលចំណាកស្រុកមិនឱ្យធ្វើការងារជាអ្នករត់តុ ឬ អ្នកកំដរអារម្មណ៍ភ្ញៀវទេ ដូច្នេះកុំទទួលការងារទាំងនេះអោយសោះ។

### ២.២.២ ការរំលោភបំពានលើសិទ្ធិការងារ

ការរំលោភបំពានសិទ្ធិការងាររួមមាន ប្រព្រឹត្តិកម្មដោយមិនយុត្តិធម៌នៅកន្លែងធ្វើការ។ ប្រការនេះអាចរួមមានទម្រង់ជាច្រើន។ វាមិនចំឡែកទេ សម្រាប់ពលករក្នុងការធ្វើការងារច្រើនម៉ោងបានទទួលប្រាក់ឈ្នួលទាប។ ពលករចំណាកស្រុកអាចធ្វើការក្នុងលក្ខខ័ណ្ឌប្រកបដោយគ្រោះថ្នាក់

កន្លែងដែល សុវត្ថិភាព និង សុខភាពពួកគេមិនត្រូវបានគិតគូរ។ វាអាចមានពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវកាយ ឬ ការយាយីផ្លូវភេទ។ ពលករខ្លះអាចត្រូវគេបណ្តេញចេញដោយអយុត្តិធម៌ ដោយសារពួកគេសុំលក្ខខ័ណ្ឌការងារឱ្យប្រសើរជាងមុន ឬដោយសារនិយោជកសម្រេចបិទកន្លែងធ្វើការដោយពុំឱ្យដំណឹង ឬដោយពុំបើកប្រាក់ផ្តាច់ពីការងារ។ ពលករទេសន្តរប្រវេសន៍មានហានិភ័យខ្ពស់ជាងពលករក្នុងស្រុក ឬឯពលករទេសន្តរប្រវេសន៍គ្មានឯកសារកាន់តែមានហានិភ័យខ្ពស់ថែមទៀត ឬទទួលការរំលោភបំពានសិទ្ធិការងារកាន់តែខ្ពស់។

### ២.២.៣ ការកេងប្រវ័ញ្ចលើការងារ

ការកេងប្រវ័ញ្ចគឺជាស្ថានភាពមួយដែលនិយោជកម្នាក់បំពានប្រើអំណាចរបស់ខ្លួន និង ប្រើនិយោជិតឱ្យធ្វើការប្រកបដោយគ្រោះថ្នាក់ ឬ ខាតប្រយោជន៍របស់និយោជិត ដើម្បីផលប្រយោជន៍របស់និយោជក។ ឧទាហរណ៍ ប្រសិនបើនៅក្នុងកិច្ចសន្យាការងារ និយោជកលើកឡើងថា គេនឹងបង់ប្រាក់មួយចំនួនដល់ពលករ ឬ ថាអោយពលករធ្វើការក្នុងចំនួនម៉ោងណាមួយ ប៉ុន្តែគេបដិសេធមិនបើកប្រាក់ឱ្យពលករ ឬប្រាប់ឱ្យធ្វើការថែមម៉ោងថែមទៀត ទង្វើនេះហៅថាការកេងប្រវ័ញ្ច។ សូចនាករទាំង ៩ ខាងក្រោមជាការកេងប្រវ័ញ្ចពលកម្មដែលកំណត់ដោយអង្គការអន្តរជាតិខាងការងារ៖

ក- ធ្វើការ ឬ ម៉ោងធ្វើការហួសកំណត់

ខ- ការងារប្រកបដោយគ្រោះថ្នាក់

គ- ប្រាក់ខែទាប និង គ្មានប្រាក់ខែ

ឃ- លក្ខខ័ណ្ឌរស់នៅអន់ខ្សោយ

ង- មិនមានការគោរពច្បាប់ការងារ ឬកិច្ចសន្យាដែលបានចុះហត្ថលេខា

ច- មិនមានការគាំពារ

ឆ- លក្ខខ័ណ្ឌការងារធ្ងន់ធ្ងរ

ជ- ការបន្លំប្រាក់ឈ្នួល

ការកេងប្រវ័ញ្ចក្លាយជាពលកម្មដោយបង្ខំនៅពេលដែលស្ថានភាពកេងប្រវ័ញ្ចចាប់ផ្តើមកើតឡើងយ៉ាងទៀងទាត់ ហើយកិច្ចព្រមព្រៀងណាមួយដែលបានធ្វើពីមុនមក គ្មានសុពលភាពដោយការដាក់ទណ្ឌកម្ម ឬ ការគំរាមកំហែង។ ពលកម្មដោយបង្ខំមានរូបភាពដូចជា៖

- ការរំលោភបំពានលើដោយប្រើកំលាំង ឬហិង្សា និង ផ្លូវភេទ
- ការបោកប្រាស់

- ការដាក់កំហិតលើការដើរហើរ
- ការដាក់អោយនៅឯកោ
- ការសម្លុត និងការគំរាមកំហែង រួមមាន ការដកហូតឯកសារអត្តសញ្ញាណ
- ការមិនបើកប្រាក់ឈ្នួលឱ្យ ឬ បំណុលទាសភាព
- លក្ខខ័ណ្ឌរស់នៅ និង លក្ខខ័ណ្ឌការងារប្រកបដោយការរំលោភបំពាន
- ធ្វើការបន្ថែមម៉ោងហួសកំណត់

នៅក្រោមច្បាប់ជាតិ និង អន្តរជាតិការរំលោភបំពាន និង ការប្រវ័ញ្ចលើសិទ្ធិការងារ គឺជាពលកម្មដោយបង្ខំ ដែលជាទង្វើខុសច្បាប់។ ពលករគប្បីត្រូវ ស្វែងរកជំនួយដើម្បីទាមទារសិទ្ធិរបស់ខ្លួនមកវិញ។ ទោះជាពលករមានការព្រមព្រៀង លើស្ថានភាពការងារនេះក៏ដោយ។ ប៉ុន្តែប្រសិនជាច្បាប់ចែងថាពលករមានសិទ្ធិទទួលបានប្រាក់ឈ្នួលអប្បបរិមា មិនមានជនណាម្នាក់គួរធ្វើកិច្ចព្រមព្រៀងជាមួយអ្នកដែលផ្តល់ប្រាក់ខែតិចជាងប្រាក់ឈ្នួលអប្បបរិមាលើការងារដែលបានធ្វើការងារពេញម៉ោងនោះទេ។ ជាសំខាន់ពលករត្រូវយល់ដឹងពីច្បាប់ឱ្យបានច្បាស់ មុនពេលចេញដំណើរទៅក្រៅ។ ដូច្នេះយើងត្រូវពន្យល់ដល់ពលករ មិនត្រូវឱ្យចុះកិច្ចសន្យាលើអ្វីដែលផ្តល់លក្ខខ័ណ្ឌមិនតាមស្តង់ដារឡើយ។[12]

### ២.២.៤ បរិយាកាសការងារគ្មានសុវត្ថិភាព ការគំរាមកំហែង

មានពលករដែលបម្រើការងារនៅក្រៅប្រទេសមួយចំនួនត្រូវបានទទួលរងគ្រោះដោយសារការកេងប្រវ័ញ្ច និង ការបន្លំប្រាក់ឈ្នួលជាដើម។

### ២.២.៥ អារម្មណ៍កណ្តោចកណ្តែង ឬ ឯកោ

ពេលធ្វើការនៅប្រទេសក្រៅ ពលករទេសន្តរប្រវេសន៍កម្ពុជាទាំងស្របច្បាប់ និងមិនស្របច្បាប់មានអារម្មណ៍ឯកោ ដោយសារឆ្ងាយពីស្រុកកំណើត ក្រុមគ្រួសារ និងសង្គមដែលពួកគេធ្លាប់រស់នៅ។ ពួកគាត់មិនអាចចែករំលែកជាមួយអ្នកដទៃ ឬ ស្វែងរកជំនួយផ្សេងទៀតបាន។

### ២.២.៦ ចំណងគ្រួសារអាចបែកបាក់

ការឆ្ងាយពីស្រុកកំណើត និង ក្រុមគ្រួសាររយៈពេលយូរ អាចធ្វើចំណងមិត្តភាព ជាមួយមិត្តភក្តិ និងជាពិសេស ចំណងគ្រួសារឱ្យមានការបែកបាក់ពីគ្នា។ ការចេញទៅបំពេញការងារនៅក្រៅ

[12] ទំព័រទី ១២៣, ១២៥, ចំណុច ៤.៣.១, ៤.៣.៣ សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ ២០០៦-២០១៥

ប្រទេសធ្វើឱ្យ បែកគ្នាឆ្ងាយ ដែលបណ្តាលឱ្យបាត់បង់វេលា ធ្វើការសន្ទនា និងការជួបមុខគ្នាច្រើនជាង ការបំពេញការងារក្នុងស្រុក

# ជំពូកទី ៣

# បណ្តាប្រទេសភាគច្រើនដែលពលករ
# កម្ពុជាធ្វើទេសន្តរប្រវេសន៍

# ជំពូកទី ៣៖ ទីផ្សារការងារដែលពលករកម្ពុជាធ្វើទេសន្តរប្រវេសន៍

## ៣.១ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេសថៃ

### ៣.១.១ស្ថានភាពរបស់ពលករខ្មែរក្រោយពីបញ្ជូនមកពីថៃវិញ

ក្រោយពីការជួយជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈស្ថានភាពពលករមានភាពប្រសើរឡើង។ ពលករមួយចំនួន កំពុងរៀបចំឯកសារ ដើម្បីទៅធ្វើការងារស្របច្បាប់។ ពលករមួយចំនួនទៀតបានវិលត្រលប់ទៅធ្វើការងារដោយស្របច្បាប់ ដោយមានការសម្របសម្រួលពីនាយកដ្ឋានមុខរបរ និង ហាត្ថពលកម្មនៃក្រសួងការងារ។ ពលករមួយចំនួនទៀតបានចូលរួមបង្កបង្កើនផលជាមួយគ្រួសាររបស់ពួកគាត់។ ពលករផ្សេងទៀតរកការងារក្នុងស្រុក។ ពលករមួយចំនួនទៀតរកការងារក្នុងស្រុកតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ។ ពលករមួយចំនួនបានចុះឈ្មោះក្នុងវគ្គបណ្តុះបណ្តាលជំនាញស្ថិតក្រោមក្រសួងការងារ ដើម្បីទទួលជំនាញ ដែលឆ្លើយតបនឹងតម្រូវការទីផ្សារ។ ពលករមួយចំនួនទៀតបានវិលប្រលប់ទៅប្រទេសថៃវិញដោយខុសច្បាប់។

### ៣.១.២ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅប្រទេសថៃ

ដើម្បីចូលធ្វើការនៅប្រទេសថៃបាន ត្រូវមានការដាក់ពាក្យសុំត្រូវធ្វើការតាមរយៈបណ្តាញស្របច្បាប់ និងមានប័ណ្ណ ការងារ និងទិដ្ឋាការធ្វើការនៅប្រទេសថៃ។ ប្រសិនបើពលករមិនមានឯកសារត្រឹមត្រូវនោះ នាំអោយត្រូវមានការចាប់ខ្លួន និងត្រូវនិរទេស។

នៅពេលពលករមានទិដ្ឋាការ ពលករត្រូវរាយការណ៍ដល់ការិយាល័យអន្តោប្រវេសន៍ក្នុងរយៈពេល ៩០ ថ្ងៃម្តង។ មន្ត្រីអន្តោប្រវេសន៍នឹងឲ្យក្រដាសមួយសន្លឹកដល់ពលករ ដែលមានកាលបរិច្ឆេទដែលពលករនឹងត្រូវរាយការណ៍នៅពេលខាងមុខ។ ពលករត្រូវរាយការណ៍ក្នុងរយៈពេល ១៥ ថ្ងៃមុនកាលបរិច្ឆេទនោះ ។ ប្រសិនបើពលកររាយការណ៍យឺតយូរជាងរយៈពេលនោះ គេនឹងពិន័យ ៥០០បាតក្នុងមួយថ្ងៃរហូត ដល់២០០០បាតជាចំនួនអតិបរិមា។

អ្នកបានទទួលការអនុញ្ញាតឲ្យធ្វើការតែជាមួយនិយោជក ដែលមានឈ្មោះលើប័ណ្ណការងារអ្នកតែប៉ុណ្ណោះ។ វាជា ការពិបាកក្នុងការដូរនិយោជក នៅពេលកំពុងធ្វើការនៅឡើយ បើព្យាយាមប្តូរនឹងអាចនាំឲ្យបាត់បង់ឯកសាររបស់អ្នក។ ប្រសិនបើអ្នកទទួលរងការកេងប្រវ័ញ្ច ឬការរំលោភបំពាន

ហើយអ្នកចង់ប្តូរនិយោជក ត្រូវទៅការិយាល័យការពារពលកម្ម និងសុខុមាលភាព ដើម្បីរាយការណ៍ដោយផ្ទាល់។[13]

ពលករទាំងអស់ត្រូវតែទទួលបានការថែទាំសុខភាព។ និយោជករបស់ពលករជាអ្នករៀបចំឲ្យពលករចូលរួមក្នុងប្រព័ន្ធរបបសន្តិសុខសង្គម។ នៅក្រោមរបបនេះ ពលករនឹងរួមវិភាគទាន ៥ ភាគរយនៃប្រាក់ខែអ្នកទៅក្នុងមូលនិធិរបបសន្តិសុខសង្គម។ ឧទាហរណ៍ ប្រសិនបើពលករបានប្រាក់ឈ្នួលអប្បបរមា៣០០បាតក្នុងមួយថ្ងៃ និងធ្វើការ២៦ថ្ងៃក្នុងមួយខែ ពលករត្រូវបើកប្រាក់បាន ៧៨០០បាត។ រដ្ឋាភិបាលនឹងកាត់៥ភាគរយពីប្រាក់ខែពលករ (៣៩០បាត) សំរាប់រួមវិភាគទានដល់របបសន្តិសុខសង្គម ដូច្នេះអ្នកនឹងទទួល ៧៤១០បាត។ និយោជកអ្នកត្រូវបង់ ៣៩០បាតរាល់ខែដល់រដ្ឋាភិបាលសំរាប់ពលករ។ និយោជកត្រូវឲ្យប័ណ្ណរបបសន្តិសុខសង្គមថៃដល់ពលករ។ ប័ណ្ណនេះនឹងប្រាប់ដល់ពលករពីមន្ទីរពេទ្យ ដែលអាចទៅពិនិត្យសុខភាពដោយឥតគិតថ្លៃ។

ប្រព័ន្ធរបបសន្តិសុខសង្គមមានអត្ថប្រយោជន៍ឯទៀតជាច្រើន ប៉ុន្តែអត្ថប្រយោជន៍ខ្លះមានការពិបាកសំរាប់ជនទេសន្តរប្រវេសន៍ក្នុងការទទួល។ ពលករអាចទទួលការផ្តល់សំណងអត្ថប្រយោជន៍មកវិញនៅពេលពួកគាត់ចាកចេញ។ ពលករត្រូវតាមដានព័ត៌មានឲ្យច្បាស់លាស់អំពីអត្ថប្រយោជន៍របបសន្តិសុខសង្គម។ ប្រសិនបើនិយោជកមិនចុះឈ្មោះពលករក្នុងប្រព័ន្ធរបបសន្តិសុខសង្គមទេ នោះពលករត្រូវទៅមន្ទីរពេទ្យ និង ចុះបញ្ជីការក្នុងគម្រោងថែទាំសុខភាពតម្លៃ៣០បាត។ អ្នកនឹងត្រូវបង់ ៦០០បាត សំរាប់ការពិនិត្យសុខភាពម្តង និងបង់ ១៣០០បាតសំរាប់មួយឆ្នាំ ហើយបន្ទាប់មកអ្នកនឹងអាចទទួលបានការថែទាំសុខភាពក្នុងតម្លៃ ៣០បាតនៅពេលទៅមន្ទីរពេទ្យម្តង។[14]

### ៣.១.៣ ស្ថានភាពពលករនៅធ្វើការខារនៅប្រទេសថៃ

ការធ្វើទេសន្តប្រវេសន៍ទៅប្រទេសថៃត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ គឺ ទេសន្តរប្រវេសន៍រយៈពេលខ្លី និង រយៈពេលវែង។ ទេសន្តរប្រវេសន៍រយៈពេលខ្លីគឺ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ទេសន្តរប្រវេសន៍រយៈពេលវែងគឺដែលមានពលករចេញពីទ្បីរួមខេត្តនានានៃប្រទេសកម្ពុជាទៅកាន់ចំណុចគោលដៅនានា នៅក្នុងប្រទេសថៃដែលមាន ពលករទេសន្តរប្រវេសន៍ភាគច្រើន គឺ ជាបុរស[15] ។

[13] ទំព័រ ១៤៩, ចំណុច ៤.៧, សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ ២០០៦-២០១៥

[14] ទំព័រ ១៥០, ១៥១, ចំណុច ៤.៧.១, សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ ២០០៦-២០១៥

[15] ទំព័រទី ១៥ ចំណុច ២.៣, ទេសន្តរប្រវេសន៍, ២០១៤

ពលករទេសន្តប្រវេសន៍ជាបុរសភាគច្រើនធ្វើដំណើរទៅប្រទេសថៃ ដើម្បីបម្រើការងារនៅក្នុងផ្នែកនេសាទលើទូក និង នៅក្នុងរោងចក្រកែច្នៃ។ ពួកគេអាចចំណូលជាមធ្យម ពី ១៥០ បាត ទៅ ១៨០ បាត ក្នុងមួយថ្ងៃ នៅក្នុងរោងចក្រកែច្នៃផលិតផលត្រី និងសម្រាប់ការនេសាទលើទូក ពួកគេទទួលបានប្រាក់ខែ ពី ៥,០០០ បាត ទៅ ៨,០០០ បាត ក្នុងមួយខែ។ ជាទូទៅពួកគេ ធ្វើការមិនទៀងទាត់ និង ធ្វើទៅតាមរដូវ ហើយភាគច្រើនធ្វើការ តែ ២សប្តាហ៍ប៉ុណ្ណោះក្នុងមួយខែ។ មានអ្នកបំលាស់ទីជាស្ត្រីផងដែរ ដែលកំពុងបម្រើការងារនៅក្នុងប្រទេសថៃ ជាទូទៅពួកគេបម្រើការងារតាមរោងចក្រ ឬ ជាអ្នកធ្វើម្ហូបអាហារ និង លក់ដូរអាជីវកម្មមួយចំនួនដូចជា ខោអាវជាដើម។

*តារាង 3 ៖ ចំនួនពលករដែលធ្វើការងារនៅប្រទេសថៃ (២០១២-២០១៤)*[16]

| ឆ្នាំ | សរុប | បុរស | ស្រី |
|---|---|---|---|
| **២០១២** | ២៦៣៩០ | ១៦៥៥១ | ៩៨៣៩ |
| **២០១៣** | ១៣៤៦៨ | ៨៨៤០ | ៤៦២៨ |
| **២០១៤** | ១៥៨៣៩ | ៩៥០១ | ៦៣៣៨ |

ស្ថិតិពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ខែមិថុនា ឆ្នាំ២០១៥)

## ៣.២ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេសម៉ាឡេស៊ី

### ៣.២.១ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅប្រទេសម៉ាឡេស៊ី

ច្បាប់អនុញ្ញាតឲ្យពលករចំណាកស្រុកកាន់លិខិតឆ្លងដែនរបស់ខ្លួន។ នៅម៉ាឡេស៊ីជាប្រការខុសច្បាប់ចំពោះ និយោជកណា ដែលដកហូតលិខិតឆ្លងដែនរបស់ពលករចំណាកស្រុក។ ប្រសិនបើអ្នកជាពលករចំណាកស្រុកស្របច្បាប់ បទបញ្ញត្តិម៉ាឡេស៊ីចែងថា និយោជកអ្នកត្រូវផ្តល់លំនៅដ្ឋានសមរម្យ។ ទោះជាយ៉ាងណាក៏ដោយអ្នកប្រហែលជាត្រូវបង់ប្រាក់ ៥០រីងហ្គីត ជា អតិបរិមារាល់ខែ ដើម្បីទូទាត់ថ្លៃលំនៅដ្ឋាន។

[16] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ខែមិថុនា ឆ្នាំ២០១៥

អនុលោមតាមបទបញ្ញត្តិនេះ ពលករចំណាកស្រុកត្រូវបង់ចំណាយថ្លៃយន្តហោះទៅកាន់ម៉ាឡេស៊ី រីឯនិយោជកត្រូវបង់ចំណាយថ្លៃយន្តហោះត្រឡប់មកវិញ។ ពលករចំណាកស្រុកក៏ទទួលបានការថែទាំសុខភាពផងដែរ ថ្វីបើវាមានអត្រាថ្លៃជាងពលករជាតិម៉ាឡេស៊ីក៏ដោយ។

ពលករចំណាកស្រុកត្រូវបានអនុញ្ញាតឲ្យជ្រើសរើស ដើម្បីធ្វើការតែក្នុងវិស័យ កសិកម្ម កមន្តសាល សេវាកម្ម និងវិស័យសំណង់ប៉ុណ្ណោះ។ ប្រសិនបើគេផ្តល់ឲ្យអ្នកនូវការងារដែលមិនដូចខាងលើនេះទេ ត្រូវប្រយ័ត្នជាទីបំផុតពីព្រោះអ្នកជ្រើសរើសនោះ ប្រហែលជាមិនស្របច្បាប់ទេ។

ប័ណ្ណការងារនៅម៉ាឡេស៊ីមានសុពលភាពរយៈពេលមួយឆ្នាំ ហើយត្រូវបន្តរាល់ឆ្នាំរហូតដល់ ៥ឆ្នាំ។ ប័ណ្ណការងារនេះមានបញ្ចូលលក្ខខណ្ឌដូចខាងក្រោម:

- អ្នកត្រូវមានអាយុយ៉ាងតិច ២១ឆ្នាំ
- ការងាររបស់អ្នកមានរយៈពេលពីរឆ្នាំ និងអាចបន្តយ៉ាងយូរបំផុតត្រឹម៥ឆ្នាំ
- និយោជកត្រូវទទួលខុសត្រូវលើការវិលត្រឡប់របស់អ្នកមកប្រទេសវិញ
- ពលករចំណាកស្រុកត្រូវទទួលបានកន្លែងស្នាក់នៅសមរម្យដោយបុរស និងស្ត្រីស្នាក់នៅផ្សេងគ្នា
- អ្នកត្រូវបានអនុញ្ញាតឲ្យធ្វើការតែជាមួយនិយោជក ដែលយកអ្នកមកម៉ាឡេស៊ីប៉ុណ្ណោះ។ លក្ខខណ្ឌនៃប័ណ្ណការងារដាក់កំហិតលើសេរីភាពបម្លាស់រកនិយោជក។ ប្រសិនបើអ្នកចាកចេញពីមុខងារដែលចែងក្នុងប័ណ្ណនេះ អ្នកនឹងក្លាយជាពលករខុសច្បាប់។
- ប័ណ្ណការងារមានសុពលភាពក្នុងរយៈពេលតែមួយឆ្នាំ ហើយត្រូវធ្វើថ្មីរាល់ឆ្នាំសំរាប់រយៈពេលបីឆ្នាំ។
- ប័ណ្ណការងារត្រូវធ្វើជាថ្មីដោយនិយោជក ក្នុងរយៈពេលបីខែមុនពេលផុតកំណត់។
- ប័ណ្ណការងារនេះមានសុពលភាពតែចំពោះនិយោជក និងវិស័យជាក់លាក់ និងមិនអាចផ្ទេរឲ្យជនដទៃឡើយ។
- ការងាររបស់អ្នកអាចត្រូវបញ្ចប់ និងប័ណ្ណការងារអាចត្រូវលុបចោលនៅពេលណាមួយក៏បានតាមច្បាប់។[17]

[17] ទំព័រ ១៥៥, ១៥៦, ១៥៧, ចំណុច ៥.៧.៣, ៥.៧.៤ សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ ២០០៦-២០១៥

### ៣.២.២ ស្ថានភាពពលករនៅធ្វើការខារនៅប្រទេសម៉ាឡេស៊ី

ចំនួនពលករទេសន្តរប្រវេសន៍ដែលបានបញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី មានចំនួនច្រើនផងដែរបើមើលធៀបនឹងប្រទេសថៃ។ ពលករដែលចេញធ្វើការនៅប្រទេសភាគច្រើនធ្វើការងារក្នុងរោងចក្រ។

ពលករទេសន្តរប្រវេសន៍ធ្វើការនៅប្រទេសម៉ាឡេស៊ី ទទួលបានប្រាក់បៀវត្សជាមធ្យមចន្លោះ ពី ១២០ ទៅ ៣៥០ ដុល្លារអាមេរិក ក្នុងមួយខែ។កិច្ចសន្យាការងាររបស់ពលករជាទូទៅគឺមានរយៈពេល ២ឆ្នាំ និងអាចពន្យាបន្ថែមបានយ៉ាងច្រើន ១ ឬ ២ឆ្នាំទៀត។

កាលពីមុនឆ្នាំ២០១០ ពលករដែលទៅធ្វើការនៅម៉ាឡេស៊ីភាគច្រើន ជាស្ត្រីដែលធ្វើការងារនៅតាមផ្ទះ ដូចជាអ្នករៀបចំថែទាំផ្ទះ អ្នកសម្អាតផ្ទះ អ្នកចំអិនអាហារ និង អ្នកថែទាំក្មេង។ ក្រោយពីឆ្នាំ ២០១០ មក រដ្ឋាភិបាលប្រទេសកម្ពុជាបានឱ្យ ការងារបម្រើតាមផ្ទះធ្វើការ កាត់បន្ថយរហូតដល់ឈប់តែម្តង ដោយសារមានបញ្ហាជាច្រើនត្រូវបានកើតឡើងលើពលករខ្មែរ។

បញ្ហា និងការប្រឈមមុខសំខាន់ៗ ដែលពលករទេសន្តរប្រវេសន៍កម្ពុជា កំពុងជួបការលំបាកនៅប្រទេសម៉ាឡេស៊ី មានដូចជា ការដកហូតឯកសារធ្វើដំណើរការទុក ការកាត់ទុកប្រាក់បៀវត្ត ឬ កាត់បន្ថយប្រាក់បៀវត្ស ការបំពានលើលក្ខខណ្ឌការងារ ខ្វះសេរីភាពក្នុងការទំនាក់ទំនង មិនអាចទទួលសេវាថែទាំសុខភាព និង ស្ត្រីទទួលការរំលោភបំពានផ្លូវភេទ។[18]

*តារាង 4 ៖ ចំនួនពលករដែលធ្វើការងារនៅប្រទេសម៉ាឡេស៊ី (២០១២-២០១៤)[19]*

| ឆ្នាំ | សរុប | បុរស | ស្រី |
|---|---|---|---|
| **២០១២** | ១៨០ | ១១០ | ៧០ |
| **២០១៣** | ៩០ | ៦២ | ២៨ |
| **២០១៤** | ៤៧០ | ១៨០ | ២៩០ |

ស្ថិតិពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ខែមិថុនា ឆ្នាំ២០១៥)

[18] ទំព័រទី ១២,១៣, ចំណុច ៣.១, ទេសន្តរប្រវេសន៍ និង ការអភិវឌ្ឍនៅកម្ពុជា, វិច្ឆិកា ២០០៩

[19] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ខែមិថុនា ឆ្នាំ២០១៥

## ៣.៣ ការធ្វើទេសន្តរប្រវេសន៍នៅប្រទេស

### ៣.៣.១ លក្ខខ័ណ្ឌការងារ និង លក្ខខ័ណ្ឌរស់នៅសាធារណៈរដ្ឋកូរ៉េ

សាធារណៈរដ្ឋកូរ៉េបានក្លាយជាប្រទេសគោលដៅមួយដ៏សំខាន់សម្រាប់ពលករបរទេសកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ។ ប្រទេសកូរ៉េបានជំនួស ប្រព័ន្ធបណ្តុះបណ្តាល ដោយប្រើប្រព័ន្ធអនុញ្ញាតការងារ (Employment Permit System = EPS) ។ ប្រព័ន្ធនេះជាមូលដ្ឋានសម្រាប់ការជ្រើសរើសកម្មករពលករ។

លក្ខខ័ណ្ឌក្នុងការធ្វើជាពលករស្របច្បាប់នៅប្រទេសកូរ៉េ។

- ត្រូវប្រលងតេស្តភាសាកូរ៉េដែលក្រសួងបានរៀបចំសហការជាមួយក្រសួងមុខរបរកូរ៉េ
- នៅពេលប្រលងជាប់ត្រូវរង់ចាំក្រុមហ៊ុននៅប្រទេសកូរ៉េជ្រើសរើស (ប្រសិនបើមិនមានក្រុមហ៊ុនណាជ្រើសរើសទេ បេក្ខជននោះក៏មិនអាចទៅធ្វើការនៅប្រទេសកូរ៉េដោយស្របច្បាប់ដែរ)
- ក្រោយក្រុមហ៊ុនកូរ៉េបានជ្រើសរើសហើយពលករត្រូវមកធ្វើតេស្តពិនិត្យសុខភាពនៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ធ្វើលិខិតឆ្លងដែន ដើម្បីរៀបចំចេញដំណើរទៅធ្វើការនៅប្រទេសកូរ៉េ។

ចំណាំះ ប្រលងតេស្តភាសាកូរ៉េជាប់ មិនមែនមានន័យថាបេក្ខជននោះមានសិទ្ធិបានចេញដំណើរទៅធ្វើការនៅប្រទេសកូរ៉េទេ គឺគ្រាន់តែពួកគាត់មានអាទិភាពក្នុងការបញ្ជូនឈ្មោះ ទៅឱ្យបណ្តាក្រុមហ៊ុនប្រទេសកូរ៉េ ជ្រើសរើសប៉ុណ្ណោះ ដូចនេះបើក្រុមហ៊ុនមិនជ្រើសរើសទេ បេក្ខជនអាចទៅធ្វើការនៅប្រទេសកូរ៉េបានទេ។

និយោជកក្រុមហ៊ុននៅប្រទេសកូរ៉េនីមួយៗត្រូវការ ពលករយ៉ាងតិច ២០នាក់ដែលជ្រើសរើសចេញតាមប្រព័ន្ធនេះ និងត្រូវធ្វើការយ៉ាងតិច ៤០ម៉ោងក្នុងមួយសប្តាហ៍។ ពលករដែលជ្រើសរើសតាមប្រព័ន្ធអនុញ្ញាតការងារនេះ នឹងទទួលបានប្រាក់សោធនសុខភាពការងារ និង កម្មវិធីសំណង់សំរាប់ពលករ។[20]

[20] របាយការណ៍លទ្ធផលការងារឆ្នាំ ២០១៤

### ៣.៣.២ ស្ថានភាពពលករទៅធ្វើការងារនៅសាធារណៈរដ្ឋកូរ៉េខាងត្បូង

តាមរយៈប្រព័ន្ធអនុញ្ញាតការងារ ពលករទេសន្តប្រវេសន៍បានទទួលប្រាក់ឈ្នួលអប្បរមាគឺ ៣.៧៧០ វុន (៣.៨០ដុល្លា) ក្នុងមួយម៉ោង។ ប្រព័ន្ធនេះ អនុញ្ញាតឱ្យប្រជាជនកម្ពុជា ទៅធ្វើការនៅប្រទេសកូរ៉េក្នុងរយៈពេលខ្លីដើម្បីទទួលបានជំនាញថ្មីៗ ដែលពួកគេអាចប្រើប្រាស់ពេលត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីរកការងារធ្វើ។ មានពលករកម្ពុជាជាច្រើនដែលកំពុងបម្រើការងារនៅប្រទេសកូរ៉េ ដែលពួកគាត់ទាំងអស់គឺជាពលករដែលធ្វើការដោយស្របច្បាប់ និងភាគច្រើនជាបុរស។[21]

*តារាង 5 ៖ ប្រភេទការងារ និង ចំនួនពលករដែលទៅធ្វើការងារនៅកូរ៉េ (២០០៧-២០១៣)*[22]

| ឆ្នាំ | ឧស្សាហកម្ម | | កសិកម្ម | | នេសាទ | | សំណង់ | | សរុបក្នុងឆ្នាំ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| **២០០៧-២០០៩** | ៣១៩១ | ២២១ | ១៣២៥ | ៥១១ | ២៦៩ | ០ | ៦៧ | ០ | ៤៧៨២ | ៧៣២ |
| **២០១០** | ១៣២៩ | ៨៣ | ៧៨៤ | ៣៩៨ | ៣ | ០ | ០ | ០ | ២១៣៦ | ៤៨២ |
| **២០១១** | ៣២៧៥ | ១៩៣ | ១៦៨១ | ៣៣០ | ១ | ០ | ០ | ០ | ៤៩៥៧ | ៥២៨ |
| **២០១២** | ៥២០៦ | ២៦៦ | ២៩១៣ | ១០៣៨ | ០ | ០ | ១៣ | ០ | ៨១៣២ | ១៣០៤ |
| **២០១៣** | ៥០២៤ | ៤៣២ | ៣១៣៣ | ១៤៥៧ | ៥ | ០ | ៦៥៨ | ០ | ៨៨២០ | ១៨៨៩ |
| **សរុប** | **១៧៩៩៥** | **១២០០** | **៩៨៣៦** | **៣៧៣៦** | **២៧៨** | **០** | **៧៣៨** | **០** | **២៨៨២៧** | **៤៩៣៤** |

ប្រភព៖ ស្ថិតិពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ខែមិថុនា ឆ្នាំ២០១៥)

[21] ទំព័រទី ១៥, ចំណុច ៣.៣, ទេសន្តរប្រវេសន៍ និង ការអភិវឌ្ឍនៅកម្ពុជា, វិច្ឆិកា ២០០៩

[22] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ខែមិថុនា ឆ្នាំ២០១៥

# ជំពូកទី ៤
# ការការពារ និង ដំណោះស្រាយកាត់បន្ថយគ្រោះថ្នាក់ការងារ

# ជំពូកទី ៤៖ ដំណោះស្រាយចំពោះគុណវិបត្តិ និងលទ្ធផលដែលសម្រេចបាន

## ៤.១ ណែនាំវិធីការពារខ្លួននឹងការរំលោភបំពានសិទ្ធិការងារដល់ពលករ

ការជួយពីក្រសួងការងារ លើ ទីភ្នាក់ជ្រើសរើសឯកជនមិនគ្រប់គ្រាន់ទេ។ ចំនេះដឹងរបស់ពលករផ្ទាល់ជាបញ្ហាសំខាន់ សម្រាប់ធ្វើការដោះស្រាយ និង រួមផុតពីគ្រោះថ្នាក់។ ពលករផ្ទាល់ក៏ត្រូវយល់ដឹងពី វិធីជាមួយចំនួនសម្រាប់ឱ្យពលករធ្វើដើម្បីការពារខ្លួនឱ្យរួចផុតពីការរំលោភបំពានលើសិទ្ធិការងារដូចជា៖

១- ប្រសិនបើ ពលករធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់ អ្នកទំនាក់ទំនងជាអ្នកទទួលការការពារប្រឆាំង នឹង ការរំលោភបំពាន។ ទោះបីជាជនទេសន្តរប្រវេសន៍គ្មានឯកសារ ក៏មិនត្រូវលើកលែងចំពោះការរំលោភបំពានណាមួយឡើយ។

២- ពលករគប្បីរក្សាទុកកិច្ចសន្យាការងារ និង កិច្ចសន្យាសេវារកការឱ្យធ្វើមួយច្បាប់ជាប់ខ្លួននៅពេលចុះហត្ថលេខា។ ចម្លងឯកសារមួយច្បាប់ទៀតនៅ ក្រសួងការងារនិង មួយច្បាប់នៅគ្រួសារ ឬ មិត្តភក្តិ។

៣- រកច្បាប់ និង គោលនយោបាយប្រទេសដែលខ្លួនត្រូវទៅ

៤- ត្រូវមានការទទួលខុសត្រូវ ប៉ុន្តែកុំអនុគ្រោះទង្វើរំលោភបំពាន

៥-ប្រសិនបើពលករនៅកន្លែងធ្វើការជាមួយពលករឯទៀត ត្រូវមានរៀបចំកិច្ចប្រជុំយ៉ាងទៀងទាត់ តែងតាំងអ្នកតំណាង ដើម្បីចរចារជាមួយនិយោជក និង ទាក់ទងក្រុមពលករឯទៀត។

៦-កសាងបណ្តាញគាំទ្រនៅប្រទេសទីតាំងដែលពលករបានធ្វើការងារ។ ត្រូវស្វែងរកនរណាដែលអាចអោយពលករសុំជំនួយបាន

## ៤.២ កាត់បន្ថយការធ្វើទេសន្តរប្រវេសន៍ក្រៅប្រទេស

ជាការពិតណាស់ការធ្វើការងារនៅក្រៅប្រទេស ពិតជាបានជួយដល់ប្រជាពលរដ្ឋ និង ជួយដល់សេដ្ឋកិច្ចប្រទេសកម្ពុជាជាច្រើន។ តែទោះជាយ៉ាងណាបញ្ហា និង ផលវិបាកមួយចំនួនក៏កើតមានច្រើនផងដែល។ ដើម្បីកាត់បន្ថយបញ្ហាដែលកើតមានឡើងទាំងនោះ រដ្ឋាភិបាលប្រទេសកម្ពុជាបានខិតខំស្វែងរកមធ្យោបាយមកដោះស្រាយ។ ការបង្កើតការងារ និង មុខរបរក្នុងស្រុក គឺជាកត្តាដ៏សំខាន់ សម្រាប់រំដោះខ្លួនចេញពីភាពក្រីក្រ។ នេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់កាត់បន្ថយភាពក្រីក្រ គឺការផ្តល់ការងារសមរម្យដែលនាំមកនូវការអភិវឌ្ឍន៍ដោយសមធម៌ និងនិរន្តរ៍ភា

៣។ ការងារសមរម្យ ត្រូវបានកំណត់និយមន័យថាជានិយមន័យថាជាការងារដែលបុរស និង ស្ត្រី អាចធ្វើបាន ក្នុងលក្ខខណ្ឌនៃសេរីភាព សមធម៌ សន្តិសុខ និង សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ព្រមទាំងអនុវត្តនិង អភិវឌ្ឍបន្ថែមលើវិស័យការងារបន្ថែមដូចជា៖

១- បន្តលើកកម្ពស់លក្ខខ័ណ្ឌការងារក្នុងឱ្យកាន់តែប្រសើរឡើង

២- បន្តពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ

៣- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងារ

៤- បន្តការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា និង អត្ថប្រយោជន៍របស់កម្មករនិយោជិត

៥- ពង្រឹងប្រព័ន្ធសុខភាព និង សុវត្ថិភាពការងារ

៦- ពង្រឹងសេវាមុខរបរ ទាំងឯកជន និង សាធារណៈទៅតាមតម្រូវនិងចំនួនពលករដែលមានជំនាញទាំងឡាយក្នុងប្រទេសកម្ពុជា

៧- ពង្រឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ[23]

## ៤.៣ វិធានការបង្កើនសុវត្ថិភាពចំណាកស្រុករបស់ក្រសួងការងារ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការខិតខំយ៉ាងខ្លាំងក្លាដើម្បីឱ្យប្រជាពលរដ្ឋដែលមានបំណងចង់ទៅធ្វើការងារនៅក្រៅប្រទេសជួបនៅភាពសុខសាន្ត និងមានសុវត្ថិភាពរហូតដល់ពេល ពួកគាត់ត្រលប់មកមាតុភូមិស្រុករបស់ពួកគាត់វិញ។ ដូច្នេះក្រៅពីមានការអប់រំដល់ពលករនូវចំនេះដឹង រួមទាំងពត៌មានសំខាន់មុនពេលចាកចេញទៅក្រៅ ក្រសួងការងារក៏មានវិធានការមួយចំនួនផ្សេងទៀតដូចជា៖

- ពង្រឹង និង ជំរុញឱ្យក្រុមហ៊ុនស្របច្បាប់ទាំងអស់ដែលបានចុះបញ្ជី ឱ្យអនុវត្តច្បាប់
- មានការវាយតម្លៃ និង ចាត់ចំណាក់ថ្នាក់លើក្រុមហ៊ុនដោយតឹងរឹងដោយមើលលើ ការជ្រើសរើស ការណែនាំតម្រង់ទិសពេលករមុនពេលចាកចេញដំណើរ ការបញ្ជូនការដាក់

[23] របាយការណ៍លទ្ធផលការងារឆ្នាំ ២០១៤ និងទិសដៅការងារអនុវត្តន៍, ឆ្នាំ២០១៥

ពាក្យឱ្យពលករធ្វើការ ការគ្រប់គ្រងការអនុវត្តកិច្ចសន្យាការងារ ការដោះស្រាយបញ្ហានានា និង ការធ្វើមាតុភូមិនិវត្តន៍របស់ពលករនៃទីភ្នាក់ងារជ្រើសរើសឯកជន

- ចុះអធិការកិច្ចការងារទីភ្នាក់ងារជ្រើសរើសឯកជន ដោយពិនិត្យលើការគ្រប់គ្រងរបស់ទីភ្នាក់ងារជ្រើសរើសឯកជន តាមរយៈ ការដាក់កំហិតលើទីភ្នាក់ងារជ្រើសរើសឯកជនដែលមិនគោរពតាមច្បាប់ អនុក្រឹត្យ និង ដាក់កំហិតលើទីភ្នាក់ងារដែលមិនគោរពលើច្បាប់ អនុក្រឹត្យ និង ការណែនាំរបស់ក្រសួង
- បង្កើតប្រព័ន្ធការងារដូចជាការធានារ៉ាប់រង ឬ ការបង់ប្រាក់ធានា ដែលទូទាត់ដោយភ្នាក់ងារជ្រើសរើសពលករ ដើម្បីសងជាសំណង ដល់ពលករទេសន្តរប្រវេសន៍ ក្នុងករណីដែលមានការខាតបង់ប្រាក់ ដែលបណ្ដាលមកពីកំហុសឆ្គងរបស់ភ្នាក់ងារជ្រើសរើសពលករ ឬ ភ្នាក់ងារដែលចុះកិច្ចសន្យាដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន។
- ផ្សព្វផ្សាយបញ្ជីទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ដែលចុះបញ្ជិកានៅក្រសួង ដល់សាធារណៈជនដើម្បីចៀសផុតពីការបោកក្រុមហ៊ុនមិនស្របច្បាប់
- បង្កើតតារាងថ្លៃឈ្នួលសេវាកម្មរកការងារឱ្យធ្វើ និង ថ្លៃឯកសារដែលពលករត្រូវចាំបាច់ត្រូវចំណាយ។
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសមន្ទីរការងារ... ខេត្ត
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយណែនាំដល់ទីភ្នាក់ងារជ្រើសរើសឯកជនពីបទប្បញ្ញត្តិនានា ដែលចាំបាច់
- តាមដាន និង ត្រួតពិនិត្យជាប្រចាំ ដល់ទីភ្នាក់ងារជ្រើសរើសពលករ ដោយទាមទាររបាយការណ៍ប្រចាំខែរបស់ក្រុមហ៊ុន
- ធ្វើការដាក់ពិន័យលើក្រុមហ៊ុនឯកជន ទៅតាមទំហំកំហុសឆ្គងនីមួយៗរបស់ទីភ្នាក់ងារជ្រើសរើសឯកជនទៅតាមនីតិវិធីជាធរមាន និងតាមកម្រិតដែលមានចែងក្នុងច្បាប់
- អនុវត្តការដាក់ទណ្ឌកម្មឱ្យមានប្រសិទ្ធភាព ចំពោះជនទាំងឡាយណាដែលរំលោភបំពាន លើសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។[24]

[24] របាយការណ៍លទ្ធផលការងារឆ្នាំ ២០១៤ និងទិសដៅការងារអនុវត្តន៍, ឆ្នាំ២០១៥

## ៤.៤ លទ្ធផលរបស់រដ្ឋាភិបាលដែលសម្រេចបាន

ភាពទន់ខ្សោយនៅក្នុងក្របខណ្ឌច្បាប់ បទបញ្ញត្តិ និងស្ថាប័នទទួលបន្ទុកទេសន្តរប្រវេសន៍ការងារ បានធ្វើឱ្យគោលនយោបាយនានាមិនមានភាពស៊ីសង្វាក់គ្នា។ បញ្ហាប្រឈមនៅក្នុងនយោបាយ នៃការការពារប្រឆាំង នឹងការពង្រឹងការអនុវត្តន៍ច្បាប់ បានកើតមាន ដែលនាំអោយមានគ្នូញត្អែរ ពីប្រជាពលរដ្ឋមួយចំនួនទាក់ទង ពីការប្តឹងទាមទារប្រាក់ឈ្នួលមានភាពយឺតយ៉ាង បញ្ហាកេងប្រវ័ញ្ចដែលកើតលើពួកគាត់ ព្រមទាំងទីកន្លែងធ្វើការមួយចំនួនគ្មាននិយាម និង សុវត្ថិភាព។ ជាធម្មតាគ្មានប្រព័ន្ធណាមួយមានភាពឥតខ្ចោះសម្រាប់ការគ្រប់គ្រង ទេសន្តរប្រវេសនោះទេ។

ទោះជាមានបញ្ហាមួយចំនួនក្តីក៏ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានខិតខំដោះស្រាយ និងទទួលបានលទ្ធផលជាច្រើនក្នុងការការពារដល់ពលករខ្មែរដែលធ្វើការក្រៅស្រុក និង ធ្វើការងារក្នុងស្រុកក្តី។

គោលនយោបាយសំខាន់ៗ និង លទ្ធផលដែលរដ្ឋាភិបាលសម្រេចបានមានដូចជាៈ

- រៀបចំសេចក្តីព្រាងច្បាប់ដែលមានលក្ខណៈទូលំទូលាយ សម្រាប់គ្រប់គ្រងដំណើរការទេសន្តរប្រវេសន៍ការងារ និង ការការពារពលករទេសន្តរប្រវេសន៍
- មានការជជែកពិភាក្សាពហុភាគី និង កិច្ចព្រមព្រៀងទ្វេភាគី ឬ អនុស្សរណៈនៃការយោគយល់គ្នាដែលទាក់ទងនឹងមុនរបរជាមួយប្រទេសទទួលពលករ ក្នុងគោលបំណងធ្វើឱ្យជាក់លាក់នូវការការពារស្រប់ច្បាប់របស់ពលករទេសន្តប្រវេសន៍។
- លុបបំបាត់ការឃោសនា និងការផ្សព្វផ្សាយមិនត្រឹមត្រូវ ដែលទាក់ទងនឹងការធ្វើទេសន្តរប្រវេសន៍ការងារ
- បង្កើតមជ្ឈមណ្ឌលព័ត៌មាននៅរាជធានី និង នៅតាមបណ្តាខេត្ត ដើម្បីផ្តល់ព័ត៌មានស្តីពីបែបបទនៃការធ្វើទេសន្តរប្រវេសន៍ការងារ ដោយចូលរួមបញ្ចូលទាំងហានិភ័យ និងការតព្វកិច្ចផ្សេងៗទៀត។
- ដាក់ចេញនូវវិធានការណ៍ ដើម្បីធានាឱ្យប្រាកដថាសេវាកម្មជ្រើសរើស និង រកការងារឱ្យធ្វើ មិនមែនជាការជ្រើសរើស ការដាក់ឱ្យធ្វើការ ឬ ប្រើប្រាស់ពលករ នៅក្នុងការងារដែលមានគ្រោះថ្នាក់ដែលមិនអាចទទួលយកបាន ការប្រព្រឹត្តដោយគ្មានសីលធម៌ ដោយរំលោភបំពាន ឬ ដោយជ្រើសរើសអើងក្នុងទម្រង់ណាមួយ។
- ជំរុញទីផ្សារការងារឱ្យប្រសើរ សម្រាប់ពលករទេសន្តរប្រវេសន៍ ដោយលើកកម្ពស់កម្រិតជំនាញរបស់ពលករ តាមរយៈផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីលើកកម្ពស់

ឱកាសការងារ របស់ពលករ និង កាត់បន្ថយភាពងាយស្រួលរងគ្រោះរបស់ពួកគេពីការកេងប្រវ័ញ្ច។[25]

- អនុវត្តដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព ចំពោះពលករទេសន្តរប្រវេសន៍ទាំងអស់ ក្នុងករណីដែលមានការរំលោភបំពាន។
- ផ្តល់សេវាកម្មច្បាប់ ស្របទៅតាមច្បាប់ជាតិ និងការអនុវត្តជាក់ស្តែង ចំពោះពលករទេសន្តរប្រវេសន៍ដែលជាភាគី បណ្តឹង ទាក់ទងនឹងមុខរបរ និងទេសន្តរប្រវេសន៍
- ផ្តល់ការបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុដល់ពលករ និង ក្រុមគ្រួសាររបស់ពួកគេ នៅដំណាក់កាលមុនពេលចេញដំណើរ
- គាំទ្រដល់ពលករទេសន្តរប្រវេសន៍ឱ្យបើកគណនី ធនាគារនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសគោលចេញដំណើរ។
- ធ្វើការកាត់បន្ថយថ្លៃសេវាផ្ទេរប្រាក់បញ្ញើ ដើម្បីសម្រួលឱ្យពលករទទួលបានសេវាហិរញ្ញវត្ថុខ្ពស់។
- លើកកម្ពស់និង ផ្តល់ការលើទឹកចិត្តដល់បង្កើត និង ការអភិវឌ្ឍន៍សហគមន៍សហគ្រាស

[25] ទំព័រ ២៨, ២៩ ចំណុច ៥.១.៥, គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់កម្ពុជា, មិថុនា ឆ្នាំ២០១០

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការធ្វើទេសន្តរប្រវេសន៍ គឺជាកត្តាដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច កាត់បន្ថយព្រមទាំងជាចំនែកមួយ រំដោះភាពក្រីក្រ និង ជួយឱ្យពលករដែលបានធ្វើទេសន្តរប្រវេសន៍ និងក្រុមគ្រួសារពលករទាំងអស់ មានជីវភាពរស់នៅបានប្រសើរជាងមុន។ រាល់ប្រាក់ចំណូលដែលពលករទេសន្តរប្រវេសន៍ ទទួលបានពីប្រាក់បៀវត្សដែលខ្ពស់ ក៏ជាចំនែកមួយក្នុងការជួយសេដ្ឋកិច្ចប្រទេសជាតិឱ្យមានការរីកចម្រើនផងដែរ ។

ទោះជាការធ្វើចំណាកស្រុកបានផ្តល់នូវផលប្រយោជន៍ច្រើនយ៉ាងណាក្តី ដល់ពលករ ប៉ុន្តែវាក៏បានផ្តល់នូវគុណវិបត្តិមួយចំនួន នៅពេលដែលពលករធ្វើទេសន្តរប្រវេសន៍ទៅរកការងារក្រៅប្រទេសផងដែរ។ មានពលករមួយចំនួនបានជួបការលំបាក និង បញ្ហាមួយចំនួននៅពេលពួកគាត់បានធ្វើចំណាកស្រុកទៅធ្វើការងារនៅប្រទេសក្រៅដែរចាកឆ្ងាយពីទីកន្លែងកំណើតរបស់ពួកគាត់។ តែដោយហេតុទីផ្សារការងារនៅខាងក្រៅមានច្រើន និង មានប្រាក់បៀវត្សខ្ពស់ ធ្វើឱ្យពួកគាត់បង្ខំចិត្តបែកពីគ្រួសារ មិត្តភ័ក្តិ ប្តីប្រព័ន្ធ។ កត្តាមួយទៀត គឺមកពីលក្ខខណ្ឌការងារមិនល្អ មិនអាចផ្គត់ផ្គង់ជីវភាពគ្រួសារ ឬ តម្រូវការក្នុងគ្រួសារខ្ពស់។

ទីផ្សារការងារដែលភាគច្រើនប្រជាពលរដ្ឋកម្ពុជា ទៅធ្វើការងារគឺនៅប្រទេសថៃ, ម៉ាឡេស៊ី និង សាធារណរដ្ឋកូរ៉េខាងត្បូងដែលនាំឱ្យពលករចាំបាច់យល់ដឹងនិងស្គាល់ពីព័ត៌មាន និង លក្ខខណ្ឌមួយចំនួនមុនពេលធ្វើចំណាកស្រុកចេញទៅធ្វើការនៅប្រទេសទាំងនោះ។

ទាំងនេះជាបញ្ហាដែលរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និង អន្តរជាតិមានភាពព្រួញបារម្ភចំពោះសុវត្ថិភាព និង ការបាត់បង់នូវកម្លាំងពលកម្មសម្រាប់បម្រើការងារនៅក្នុងប្រទេស។ ដូច្នេះរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និង អន្តរជាតិ ត្រូវស្វែងរកវិធានការមួយចំនួនដើម្បីជួយដល់ពលករ និង កាត់បន្ថយរាល់ផលលំបាកដែលកើតលើរូបគាត់ និង សេដ្ឋកិច្ចជាតិ។

# អនុសាសន៍

# អនុសាសន៍

ក្នុងពេលឆាប់ៗនេះ ទីផ្សារតំបន់តែមួយ ដែលត្រូវបានគេបង្កើតឡើងក្រោមគម្រោងសហគមន៍សេដ្ឋកិច្ចអាស៊ាន នឹងត្រូវបានកំណត់ដែលមាន ផលិតផល សេវាកម្ម មូលធន និង កម្លាំងពលកម្មជំនាញ នឹងធ្វើចលនាបំលាស់ទីនៅក្នុងតំបន់ដោយសេរី។ ការអភិវឌ្ឍន៍ទាំងនេះ នឹងនាំមកនូវការតាំងទីលំនៅថ្មី និងឧស្សាហកម្មអតិពលកម្មនៅក្នុង ចំណោមប្រទេសជាសមាជិកអាស៊ាន ដែលនាំមកនូវទីផ្សារការងារជាច្រើន ដល់ប្រជាជននៅប្រទេសកម្ពុជាយើងនៅពេលអនាគត។

ម្យ៉ាងវិញទៀត ពេលបច្ចុប្បន្នវិស័យការងារនៅប្រទេសកម្ពុជាមាន លក្ខណៈល្អប្រសើរជាងមុនដោយមានការកាត់បន្ថយរាល់បញ្ហាដែលធ្លាប់កើតមានដូចជាការកេងប្រវ័ញ្ចជាដើម។ មិនត្រឹមតែប៉ុណ្ណោះ ទីផ្សារការងារក្នុងស្រុក ច្រើនប្រកបដោយប្រាក់បៀវត្សច្រើន ល្មមនឹងការរស់នៅប្រចាំថ្ងៃព្រមទាំង សល់ប្រាក់សម្រាប់ចំណាយផ្សេងៗ ដែលពលករអាចរស់នៅបានយ៉ាងស្រួលនៅក្នុងស្រុក។ ការធ្វើការងារក្នុងស្រុកក៏បាន ធានានូវសុវត្ថិភាពបានច្រើនជាងការទៅ ធ្វើចំណាកស្រុករកការងារនៅប្រទេសក្រៅផងដែរ។

ដូច្នេះខ្ញុំសូមលើកទឹកចិត្តឱ្យបងប្អូន ប្រជាពលរដ្ឋ ពលករទាំងអស់ ពិនិត្យលើការងារក្នុងស្រុក។ សូមកត់សម្គាល់ថា ទីផ្សារការងារល្អក្នុងស្រុក មានកាន់តែច្រើន លើលក្ខខណ្ឌការងារក៏កាន់តែប្រសើរសម្រាប់បងប្អូន ម្យ៉ាងវិញទៀតបាននៅជិតក្រុមគ្រួសារ និងមានភាពងាយស្រួលក្នុងការរស់នៅ ដូចជាការធ្វើដំណើរ ការឈប់សម្រាក ការហូបចុក។

មុននឹងធ្វើចំណាកស្រុកសូមបងប្អូនគួរតែពិចារណាលើផលវិជ្ជមាន និង ផលអវិជ្ជមាន នៃការចំណាកស្រុកឱ្យបានច្បាស់។ ម្យ៉ាងទៀត ត្រូវសិក្សាឱ្យបានច្បាស់លាស់ពីផលប៉ះពាល់មុនសម្រេចចិត្តធ្វើចំណាកស្រុក ប្រសិនបើមានបំនងធ្វើចំណាកស្រុកទៅក្រៅប្រទេស។

មុនពេលចេញទៅធ្វើការងារនៅក្រៅ ប្រជាពលរដ្ឋ ពលករ ទាំងអស់ត្រូវធ្វើការពិនិត្យឱ្យបានម៉ត់ចត់ជាមុនសិន ដូចជាត្រូវ ពិនិត្យមើលទៅលើក្រុមហ៊ុនណា ដែលជាក្រុមហ៊ុនស្របច្បាប់ (មានន័យថា ក្រុមហ៊ុនដែលបានចុះបញ្ជីកាទទួលស្គាល់ពីក្រសួងការងារ) ជាពិសេសគួរទំនាក់ទំនងជាមួយ ក្រសួងការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្មជាមុនសិន មុននឹងធ្វើការសម្រេចចិត្តទៅធ្វើការងារនៅបរទេស។

ជាពិសេសមុននឹងចាកចេញទៅធ្វើការនៅបរទេស ត្រូវពិនិត្យមើលនូវរាល់ឯកសារស្រប ច្បាប់ជាមុនសិន ចៀសវាងមានការឆបោក ឬ តាមរយៈមេខ្យល់ណាមួយ ដែលកេងយកផល ប្រយោជន៍ ឬ កេងចំណេញពីបងប្អូន ប្រជាពលរដ្ឋ និងពលករ៕

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស


- របាយការណ៍លទ្ធផលការងារឆ្នាំ ២០១៤ និងទិសដៅការងារអនុវត្តន៍ (ឆ្នាំ២០១៥)
- ទេសន្តរប្រវេសន៍ និង ការអភិវឌ្ឍនៅកម្ពុជា (២០០៩)
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឆ្នាំ២០១៥)
- សៀវភៅណែនាំទេសន្តរប្រវេសន៍ ឆ្នាំ (២០០៦-២០១៥)
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ៖ ជរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ២០០៨
- វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៧
- Cambodia : Toward a National Employment Strategy for Sustained Poverty Reduction (2012)
- General survey concerning employment instruments (2010)
- Effective Protection for Domestic Worker: A Guide to Designing Labour Laws (May,2012)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- អនុក្រឹត្យស្តីពី ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈ ទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសស្តីពី សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការនិងការធ្វើមាតុភូមិនិវត្តន៍
- ប្រកាសស្តីពី កិច្ចសន្យាសេវាការងារឱ្យធ្វើនៅបរទេស
- ប្រកាសស្តីពី ដំណើរការជ្រើសរើស និងការណែនាំសម្រង់ទិសពលករមុនពេលចេញដំណើរ
- ប្រកាសស្តីពី ការដាក់ឱ្យប្រើពាក្យគន្លឹះ
- ប្រកាសស្តីពី ការសរសើរ និង ការដាក់វិន័យទីភ្នាក់ជ្រើសរើសឯកជន
- ប្រកាសស្តីពី ទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសស្តីពី អធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសស្តីពី យន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍
- អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ ស្តីពីកិច្ចសហប្រតិបត្តិការនៃការប្រើប្រាស់ពលកម្ម